# គណៈកម្មការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW) របាយការណ៍ស្រមោល



ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ ២០១៣

## របាយការណ៍រៀបចំឡើង ក្រោមកិច្ចសហការជាមួយគណៈកម្មាធិការស្ត្រីកម្ពុជា

ការវាយតម្លៃលើការវិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តន៍អនុសញ្ញានៃអង្គការសហប្រជាជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ

**NGO-CEDAW ជាសម្ព័ន្ធនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា និងបណ្តាញការងារចំនួន ៩០ ដែលបានប្តេជ្ញាចិត្ត ដើម្បីវឌ្ឍនភាពរបស់ស្ត្រី។**

គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW) បានបង្កើតឡើងនៅឆ្នាំ ១៩៩៥ ដោយមានជំនួយគាំទ្រពីឧត្តមស្នងការជាន់ខ្ពស់របស់អង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំនៅកម្ពុជា (COHCHR)។ ពីដំបូង NGO-CEDAW មានអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាចំនួន ៩ ដែលជាសមាជិក។ បច្ចុប្បន្ន NGO-CEDAW មានសមាជិកអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាចំនួន ៧៩។ បេសកម្មសំខាន់របស់ NGO-CEDAW គឺ ធ្វើការត្រួតពិនិត្យ និង ផ្តល់នូវរបាយការណ៍ឯករាជ្យ ស្តីពីការវិវឌ្ឍន៍ក្នុងការអនុវត្តន៍អនុសញ្ញា ស៊ី ដវ នៅក្នុងប្រទេសកម្ពុជា។ ក្នុងនាមជាសម្ព័ន្ធអង្គការដែលធ្វើការដើម្បីស្ត្រី សកម្មភាពនានានៃសមាជិករបស់ NGO-CEDAW គ្របដណ្តប់វិស័យភាគច្រើននៃសកម្មភាព និងសង្គម។ សមាជិក NGO-CEDAW មានការចាប់អារម្មណ៍ដោយផ្ទាល់លើដំណើរការបោះឆ្នោត ហើយបានចូលរួមចំណែកយ៉ាងសកម្ម ក្នុងការផ្តល់ការគាំទ្រតាមរយៈការបញ្ជូនអ្នកអង្កេតការបោះឆ្នោតរបស់ខ្លួន។


សំរាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង:

លោកស្រីវេជ្ជ. **ពុង ឈីវកេក** ប្រធាន NGO-CEDAW

E–mail : licadhomail@gmail.com

លោកស្រី **ចឹម ចាន់នាង** អ្នកសម្របសម្រួល

E–mail : ngocedaw.pnh@gmail.com

អាសយដ្ឋាន: ផ្ទះលេខ ១៦ ផ្លូវលេខ ៩៩ ភ្នំពេញ ប្រទេសកម្ពុជា

Web : www.ngocedaw.org

**គណៈកម្មាធិការស្ត្រីកម្ពុជា (CAMBOW)**

CAMBOW ជាសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាល និងបណ្តាញការងារចំនួន ៣៥ ដែលបានប្តេជ្ញាចិត្ត ដើម្បីវឌ្ឍនភាពរបស់ស្ត្រី និងកុមារ។ CAMBOW បានបង្កើតឡើងនៅឆ្នាំ ២០០០ ដែលមានគោលបំណងសំខាន់ៗ រួមមាន៖

- ចូលរួមចំណែកក្នុងការបោះពុម្ពផ្សាយរបាយការណ៍ស្រមោល ស្របពេល ដែលរដ្ឋាភិបាល ធ្វើការរាយការណ៍ទៅគណៈកម្មាធិការនៃអង្គការសហប្រជាជាតិ ទទួលបន្ទុកអនុសញ្ញា ស៊ីដរ
- ចូលរួមក្នុងសកម្មភាពពាក់ព័ន្ធនឹងការបញ្ចប់អំពើហិង្សាលើស្ត្រី និងកុមារ ដោយរួមសហការជាមួយ NGO-CEDAW
- សម្របសម្រួលគំនិតផ្តួចផ្តើមក្នុងការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិរបស់ស្ត្រី តាមរយៈយុទ្ធនាការមហាជន និងប្រព័ន្ធផ្សព្វផ្សាយ ព្រមទាំងព្រឹត្តិការណ៍ពិសេសនានា ដូចជា យុទ្ធនាការបំពាក់បូពណ៌សរ ១៦ ថ្ងៃ ដើម្បីប្រឆាំងនឹងអំពើហិង្សាលើយេនឌ័រ និងទិវាកុមារអន្តរជាតិ នៅថ្ងៃទី ១ ខែមិថុនា
- សម្របសម្រួលការផ្លាស់ប្តូរព័ត៌មាន និងសេវាទៅវិញទៅមក ក្នុងចំណោមអង្គការដែលជាសមាជិក និងអង្គការដទៃទៀត
- សម្របសម្រួលការកសាងសមត្ថភាពអង្គការដែលជាសមាជិក សង្គមស៊ីវិល ក្រុមមន្ត្រី

សំរាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង:

លោកស្រីវេជ្ជ. **ពុង ឈីវកេក** ប្រធាន NGO-CEDAW

E–mail: licadhomail@gmail.com
E–mail: cambowmail@gmail.com

អាសយដ្ឋាន: ផ្ទះលេខ ១៦ ផ្លូវលេខ ៩៩ ភ្នំពេញ ប្រទេសកម្ពុជា

Tel.: (+855) 12 802 506

# មាតិកា


អនុសាសន៍ ........ 4

សេចក្តីផ្តល់មតិទូទៅ ........ 6

មាត្រា ១៖ និយមន័យ នៃពាក្យ "ការរើសអើងលើស្ត្រីភេទ" ........ 7

មាត្រា ២៖ កាតព្វកិច្ចក្នុងការលុបបំបាត់ការរើសអើង ........ 8

មាត្រា ៣ និង ៤៖ ការអភិវឌ្ឍន៍ និងវឌ្ឍនភាពរបស់ស្ត្រី ការពន្លឿនឲ្យមានសមភាពរវាងបុរស និងស្ត្រី ........ 9

មាត្រា ៥៖ តួនាទីភេទ និងផ្នត់គំនិត ........ 10

មាត្រា ៦៖ ការធ្វើអាជីវកម្មលើស្ត្រី ........ 11

មាត្រា៧៖ ជីវិភាពនយោបាយ និងសង្គម ........ 12

មាត្រា៩៖ សញ្ជាតិ ........ 14

មាត្រា ១០៖ ការអប់រំ ........ 14

មាត្រា១១៖ ការងារ ........ 15

មាត្រា ១២៖ ភាពស្មើគ្នាក្នុងការទទួលបានការថែទាំសុខភាព ........ 17

មាត្រា ១៣៖ ផលប្រយោជន៍សេដ្ឋកិច្ច និងសង្គម ........ 19

មាត្រា ១៤៖ ស្ត្រីនៅតាមជនបទ ........ 19

មាត្រា ១៥៖ ភាពស្មើគ្នាចំពោះមុខច្បាប់ និងក្នុងបញ្ហារដ្ឋប្បវេណី ........ 22

មាត្រា ១៦៖ ភាពស្មើគ្នានៅក្នុងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ........ 23

អនុសាសន៍ទូទៅ ១៩៖ អំពើហិង្សាលើស្ត្រី ........ 25

# អនុសាសន៍

- ធ្វើវិសោធនកម្ម និងផ្សព្វផ្សាយ ច្បាប់ បទបញ្ញា បទបញ្ញត្តិ និងគោលនយោបាយនានា ដើម្បីដាក់បញ្ចូលនិយមន័យច្បាស់លាស់នៃ"ការរើសអើង" ដូចមានចែងនៅក្នុង អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (CEDAW) (ស៊ី ដវ)។
- ធ្វើការពិនិត្យឡើងវិញឲ្យបានហ្មត់ចត់លើច្បាប់ បទបញ្ញា បទបញ្ញត្តិ និងគោលនយោបាយទាំងអស់ ហើយកែប្រែច្បាប់ បទបញ្ញា និងបទបញ្ញត្តិទាំងអស់នោះ ដើម្បីលុបចេញនូវ ពាក្យពេចន៍ ឬ ភាសារដែលមានលក្ខណៈរើសអើងលើស្ត្រី។
- អប់រំសាធារណជន អំពីរបៀបដាក់ពាក្យបណ្តឹង នៅពេលដែលសិទ្ធិរបស់អ្នកទាំងនោះត្រូវបានរំលោភបំពាន ហើយបង្កើតយន្តការផ្សេងៗ ដើម្បីធានានូវសុវត្ថិភាពដល់អ្នកដាក់ពាក្យបណ្តឹងទាំងនោះ។
- ពង្រឹង និងអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយឆ្នាំ ២០១០ ដោយរួមទាំងផ្តល់ការការពារចំពោះអ្នកផ្តល់ព័ត៌មាន និងបង្កើនទោសទណ្ឌ ចំពោះការប្រព្រឹត្តអំពើពុករលួយ ជាពិសេស កិច្ចខិតខំប្រឹងប្រែងទាំងឡាយណា សំដៅលុបបំបាត់ការរើសអើងលើស្ត្រី និងកុមារី។
- ផ្តល់ភាពអង់អាចដល់ក្រសួងកិច្ចការនារី ដើម្បីធ្វើការត្រួតពិនិត្យលើសកម្មភាពរបស់អាជ្ញាធរអនុវត្តច្បាប់ និង ស្ថាប័នរដ្ឋ ទាក់ទងនឹងការមិនរើសអើងលើស្ត្រី។
- សូមផ្តល់វគ្គបណ្តុះបណ្តាលដល់ព្រឹទ្ធសភា និងមន្ត្រីអនុវត្តច្បាប់អំពីអនុសញ្ញា ស៊ី ដវ ដើម្បីជម្រុញឲ្យមានការអនុវត្តប្រកបដោយប្រសិទ្ធភាពទៅលើច្បាប់ដែលមានស្រាប់ ។
- រក្សា និងបន្ថែមចំនួនកូតាសម្រាប់ស្ត្រីនៅក្នុងជួរដ្ឋាភិបាល។
- អនុម័តច្បាប់ស្តីពីការការពារជនរងគ្រោះ ដើម្បីការពារស្ត្រីប្រកបរបរផ្លូវភេទ និងបណ្តុះបណ្តាលច្បាប់នេះដល់មន្ត្រីអនុវត្តច្បាប់។
- ចំពោះការប្រព្រឹត្តមកលើជនរងគ្រោះ រាជរដ្ឋាភិបាលកម្ពុជាគួរផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការយល់ដឹងពាក់ព័ន្ធនឹងយេនឌ័រ។
- ដាក់ឲ្យអនុវត្តច្បាប់នានា ដែលទប់ស្កាត់មិនឲ្យមានការរើសអើងលើស្ត្រីមានផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ ព្រមទាំងស្ត្រីប្រកបរបរផ្លូវភេទផងដែរ។
- បង្កើតមូលនិធិពិសេសមួយ ដើម្បីផ្តល់ជំនួយផ្នែកច្បាប់ និងធនធានផ្សេងៗដល់ជនរងគ្រោះ ដោយសារការជួញដូរផ្លូវភេទ ការជួញដូរមនុស្ស ការរំលោភសេពសន្ថវៈ និងដោយសារការធ្វើពេស្យាកម្ម។

- បង្កើនកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ព្រមទាំងបង្កើនខ្ទង់ចំណាយផងដែរ ទៅលើកម្មវិធីស្តារលិទ្ធភាពឡើងវិញដល់អ្នកធ្លាប់ប្រកបរបរផ្លូវភេទ។
- ដកចេញបញ្ញត្តិនៃច្បាប់អាពាហ៍ពិពាហ៍ដែលមានភាពរើសអើង ទាក់ទងនឹងការរៀបការជាមួយជនបរទេស និងរិះរកមធ្យោបាយផ្សេងៗក្នុងការកាត់បន្ថយការជួញដូរផ្លូវភេទ។
- លុបចេញការរឹតត្បិតលើប្រជាពលរដ្ឋខ្មែរដែលរស់នៅបរទេស ទាក់ទងនឹងការបោះឆ្នោត។
- សាងសង់កន្លែងស្នាក់នៅដែលមានសុវត្ថិភាពនៅក្នុងទីក្រុង សម្រាប់និស្សិតស្រី។
- បង្កើនប្រាក់បៀវត្សរបស់គ្រូបង្រៀន ដែលជាមធ្យោបាយមួយ ក្នុងចំណោមធ្យោបាយផ្សេងទៀត ដើម្បីលុបបំបាត់អំពើពុករលួយ។
- រាជរដ្ឋាភិបាលកម្ពុជាគួរធានាថា ការផ្តល់ការអប់រំដល់ជនជាតិភាគតិច ត្រូវប្រកបដោយសមភាព។
- បង្កើនប្រាក់ឈ្នួលអប្បបរមាជាតិ ជាពិសេសសំរាប់កម្មកររោងចក្រកាត់ដេរ។
- កែលម្អលក្ខខណ្ឌការងារនៅក្នុងរោងចក្រកាត់ដេរ។
- ចាត់វិធានការ ដើម្បីលុបបំបាត់ការរំលោភបំពានទៅលើកម្មករចំណាកស្រុក។
- រាជរដ្ឋាភិបាលកម្ពុជាគួរផ្តល់ការធ្វើតេសជម្ងឺមហារីកសុដន់ និងស្បូនដោយឥតគិតថ្លៃ។
- បង្កើនសមត្ថភាពពេទ្យឆ្មប ក្នុងការផ្តល់ការប្រឹក្សាដល់ស្ត្រី និងជួយដល់ការពន្យារកំណើត។
- ចេញបទបញ្ញត្តិនៃច្បាប់ សំរាប់វិស័យឧស្សាហកម្ម និងសហគ្រាសខ្នាតតូច ដើម្បីអនុញ្ញាតឲ្យនយោជិកជាស្ត្រីបានចូលរួមក្នុងកម្មវិធីអប់រំសុខភាព។
- រាជរដ្ឋាភិបាលកម្ពុជាត្រូវធ្វើការកែទម្រង់គោលនយោបាយ និងច្បាប់ទាំងអស់ ដែលទាក់ទងនឹងការប្រព្រឹត្តមកលើអ្នកផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ និងអ្នកថែទាំពួកគេ ដើម្បីធានាថា ប្រជាជនដែលងាយរងគ្រោះ ដូចជា អ្នកប្រើប្រាស់ថ្នាំញៀន ស្ត្រីមានផ្ទៃពោះ និងអ្នកផ្សេងទៀត ទទួលបានការថែទាំសុខភាព។
- រាជរដ្ឋាភិបាលកម្ពុជាត្រូវបើកវគ្គបណ្តុះបណ្តាលបន្ថែមទៀតដល់មន្ត្រីនគរបាល និងអាជ្ញាធរអនុវត្តច្បាប់ ដើម្បីទប់ស្កាត់ពួកគាត់កុំឲ្យចាប់ខ្លួនបុគ្គលដែលគ្រាន់តែដាក់ស្រោមអនាម័យតាមខ្លួន។
- ផ្តល់សេវាសុខភាពដល់ប្រជាពលរដ្ឋដែលងាយរងគ្រោះបំផុត រួមទាំងបុរស និងស្ត្រីស្រឡាញ់ភេទដូចគ្នា និងបុរសស្ត្រីដែលកែភេទ អ្នកប្រើប្រាស់ថ្នាំញៀន និងអ្នកប្រកបរបរផ្លូវភេទ ដោយមិនផាត់ពួកគាត់ចេញពីសង្គមឡើយ។

- បង្កើនគោលនយោបាយសំរាប់កិច្ចអន្តរាគមន៍ និងផែនការនានាទៅក្នុងយុទ្ធសាស្រ្តថ្នាក់ជាតិ ទាក់ទងទៅនឹងកុមារកំព្រា និងកុមារងាយរងគ្រោះ។
- ធ្វើវិសោធនកម្មច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ដើម្បីឲ្យស្ត្រី និងបុរសមានសិទ្ធិស្មើគ្នា ក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍។
- រាជរដ្ឋាភិបាលគួរផ្តល់ប្រាក់កម្ចី ដោយមានអត្រាការប្រាក់អប្បបរិមាដល់ស្ត្រីនៅជនបទ។
- រាជរដ្ឋាភិបាលគួរបង្កើនចំនួនអាហាររូបករណ៍សម្រាប់កុមារនៅជនបទ។
- ក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ និងក្រសួងកិច្ចការនារី ត្រូវសហការជាមួយអជ្ញាធរមូលដ្ឋាន ដើម្បីពង្រឹងការឆ្លើយតប និងយន្តការផ្លូវច្បាប់របស់រដ្ឋាភិបាល ចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមមានការរំលោភសេពសន្ថវៈ អំពើហិង្សាក្នុងគ្រួសារ…។ល។
- រាជរដ្ឋាភិបាលកម្ពុជាគួរបង្កើតបទបញ្ញត្តិ ដែលអនុញ្ញាតឲ្យស្ត្រីធ្វើការសម្រេចចិត្តជាឯកតោភាគីក្នុងការលែងលះ ដោយមិនចាំបាច់មានការផ្សះផ្សា។
- ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ស្ត្រី ដើម្បីជម្រុញឲ្យពួកគាត់មានឯករាជ្យភាពផ្នែកថវិកា និងកាត់បន្ថយចំនួនស្ត្រីរងគ្រោះ ដែលត្រូវបង្ខំចិត្តរស់នៅក្នុងចំណងអាពាហ៍ពិពាហ៍ដែលពោពេញទៅដោយការរំលោភបំពាន ជាពិសេសស្ត្រីដែលមានស្វាមីជាប់ពន្ធនាគារដោយសារការប្រព្រឹត្តអំពើហិង្សា និងស្ត្រីដែលត្រូវចិញ្ចឹមគ្រួសារតែម្នាក់ឯង។
- រាជរដ្ឋាភិបាលកម្ពុជាគួរលើកកម្ពស់ និងពង្រឹងការអនុវត្តន៍ក្រមសីលធម៌របស់នគរបាល តាមរយៈវគ្គបណ្តុះបណ្តាល។ រាជរដ្ឋាភិបាលកម្ពុជាគួរកែលម្អផងដែរនូវយន្តការនានាសម្រាប់ធ្វើការត្រួតពិនិត្យ និងវាយតម្លៃមន្ត្រីនគរបាល ក្នុងគោលបំណងបង្កើនគណនេយ្យភាព។
- គួរបង្កើនទម្ងន់ទោសបន្ថែមទៀត ចំពោះអ្នករំលោភច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ។
- កែលម្អប្រព័ន្ធអប់រំ និងជម្រុញលើកទឹកចិត្តឲ្យកុមារីបន្តការសិក្សា។

## សេចក្តីផ្តល់មតិទូទៅ

នៅក្នុងរបាយការណ៍គួបថ្នាក់ជាតិ លើកទី៤ និងទី៥ ឆ្នាំ២០១០ របស់រាជរដ្ឋាភិបាល

កម្ពុជា ស្តីពីការអនុវត្តន៍អនុសញ្ញាអន្តរជាតិ ក្នុងការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទនៅកម្ពុជា បានធ្វើសេចក្តីយោងយ៉ាងជាក់លាក់ទៅនឹងបទប្បញ្ញត្តិនៅក្នុងរដ្ឋធម្មនុញ្ញ និងនៅក្នុងក្រមព្រហ្មទណ្ឌ ដោយអះអាងថា អត្ថិភាពនៃបទប្បញ្ញត្តិទាំងអស់នេះ រួមទាំងច្បាប់បន្ថែមនានាដែលគ្រោងនឹងអនុម័តនាថ្ងៃខាងមុខ ត្រូវជានាឲ្យមានសមភាពពេញលេញរវាងស្ត្រី និងបុរស ក្នុងការទទួលបានការការពារ និងការអាស្រ័យផលពីសិទ្ធិមនុស្សរបស់ពួកគាត់ ព្រមទាំងទទួលបានការការពារពីគ្រប់ទម្រង់នៃការរើសអើង។ ការអនុម័តច្បាប់ដែលធានាដល់ការការពារស្មើភាពគ្នាចំពោះស្ត្រី និងភាពគ្មានការរើសអើង មិនគួរយល់ច្រឡំថា មានភាពដូចគ្នានឹងការផ្តល់ឲ្យជាក់ស្តែងនូវសិទ្ធិស្មើគ្នា និងការអនុវត្តន៍គ្មានការរើសអើងពិតប្រាកដនោះទេ ហើយការធ្វើឲ្យមានសិទ្ធិស្មើគ្នាពិតប្រាកដ និងការអនុវត្តគ្មានការរើសអើងពិតប្រាកដនេះ ទើបជាការអនុលោមតាមស្មារតី និងគោលបំណងនៃអនុសញ្ញាស៊ី ដវ។

ចាប់តាំងពីរបាយការណ៍ជាតិចុងក្រោយមក រាជរដ្ឋាភិបាលបានសម្រេចនូវការរីកចម្រើនតិចតួចប៉ុណ្ណោះ ទាក់ទងនឹងការអនុវត្តតាមស្មារតី និងគោលបំណងនៃអនុសញ្ញាស៊ីដវ។ ភាពមិនវិវឌ្ឍន៍ទៅមុខក្លាយជារឿងធម្មតា ហើយមានផ្នែកខ្លះកំពុងតែដើរថយក្រោយទៀតផង។

## មាត្រា ១៖ និយមន័យ នៃពាក្យ "ការរើសអើងលើស្ត្រីភេទ"

រាជរដ្ឋាភិបាលកម្ពុជាថ្លែងថា ការឲ្យនិយមន័យនៃពាក្យ 'ការរើសអើងលើស្ត្រីភេទ' គឺដូចនឹងការកំណត់និយមន័យនៅក្នុងអនុសញ្ញាស៊ី ដវ។ ទោះជាយ៉ាងណា មិនឃើញមាននិយមន័យត្រឹមត្រូវណាមួយ ត្រូវបានដាក់បញ្ចូលនៅក្នុងច្បាប់ដែលពាក់ព័ន្ធនោះឡើយ ហើយក៏មិនបានធ្វើសេចក្តីយោងជាក់លាក់ និងច្បាស់លាស់ណាមួយ ទៅនឹងមាត្រា ១ នៃអនុសញ្ញាស៊ី ដវនេះដែរ។

ពុំមានទិន្នន័យស្តីពីការរំលោភបំពានលើមាត្រានានានៃក្រមព្រហ្មទណ្ឌ ថាតើមានប៉ុន្មានករណី ហើយករណីទាំងនេះត្រូវបានរំលោភបំពានដោយរបៀបណា។ មិនមានបណ្តឹងទៅលើការរំលោភបំពានទាំងនឹង ដាក់ទៅតុលាការនោះទេ។ ដោយសារកង្វះការរាយការណ៍ដូច្នេះ គេមិនដឹងថា តើមានស្ត្រីប៉ុន្មាននាក់ ដែលប្រឈមនឹងការរើសអើងទាក់ទងនឹងយេនឌ័រនោះដែរ។

## មាត្រា ២៖ កាតព្វកិច្ចក្នុងការលុបបំបាត់ការរើសអើង

រាជរដ្ឋាភិបាលកម្ពុជាមិនទាន់បានកំណត់និយមន័យនៃការរើសអើង ហេតុដូច្នេះហើយ ការហាមឃាត់មិនឲ្យមានការរើសអើង ដែលមានចែងនៅក្នុងមាត្រា ៩៥ នៃច្បាប់រដ្ឋធម្មនុញ្ញ គឺមិនមានន័យ ឬក៏មិនមានទម្ងន់តាមផ្លូវច្បាប់នោះឡើយ។

រាជរដ្ឋាភិបាលកម្ពុជាបានរាយឈ្មោះបទបញ្ញត្តិ និងវិធានការផ្សេងៗ ដែលខ្លួនបានអនុម័ត ដើម្បីហាមឃាត់ការរើសអើងលើស្ត្រីភេទ ប៉ុន្តែទោះបីជាយ៉ាងក៏ដោយ ជាក់ស្តែង ពាក្យពេជន៍ និងភាសានៃបទប្បញ្ញត្តិជាច្រើនទាំងនេះ មានលក្ខណៈរើសអើងជារៀងរហូតមក ហើយមិនបានផ្តល់ការការពារ និងសិទ្ធិស្មើភាពគ្នាដល់ស្ត្រីនោះទេ។ អំពើពុករលួយនៅក្នុងប្រព័ន្ធច្បាប់ និងកង្វះការយល់ដឹងនៅទីជនបទ ជាកត្តាចំបងពីរ ដែលធ្វើឲ្យការអនុវត្តមាត្រា ៩៥នេះ មិនមានប្រសិទ្ធភាព ឬ មិនមានឥទ្ធិពលពិតប្រាកដក្នុងការបញ្ឈប់ការរើសអើងលើស្ត្រីឡើយ។

នៅទីជនបទជាពិសេស ជារឿយៗ ច្បាប់ត្រូវបានមើលរំលង និងមិនត្រូវបានយកទៅផ្សព្វផ្សាយដល់ប្រជាពលរដ្ឋនៅតំបន់នោះទេ ឬដល់អាជ្ញាធរដែលទទួលខុសត្រូវក្នុងការអនុវត្ត និងការដាក់ឲ្យអនុវត្តច្បាប់នោះដែរ។ ចំពោះករណីខ្លះ អាជ្ញាធរយល់ដឹងអំពីច្បាប់ ប៉ុន្តែដោយសារអំពើពុករលួយ អាជ្ញាធរទាំងនោះ មិនអនុវត្តតាមច្បាប់នោះទេ នៅពេលដែលស្ត្រីព្យាយាមប្រើប្រាស់សិទ្ធិរបស់ខ្លួន ដូចដែលមានចែងនៅក្នុងច្បាប់។ នេះមិនមែនជារឿងចម្លែកនោះទេ ដែលចៅក្រមកាន់ជើងបុរសជាងស្ត្រី នៅអំឡុងពេលសវនាការ បញ្ហានេះកើតឡើងដោយសារកត្តាយេនឌ័រតែម្តង ឬ ដោយសារបុរសមានលុយច្រើនជាងស្ត្រី ហើយអាចផ្តល់សំណូកដល់ចៅក្រម។

រាជរដ្ឋាភិបាលកម្ពុជាបានសរសេរនៅក្នុងរបាយការណ៍ជាតិថា ខ្លួនបានចាត់តាំងក្រសួងកិច្ចការនារី និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ឲ្យធ្វើការត្រួតពិនិត្យលើសកម្មភាពរបស់អាជ្ញាធរ និងស្ថាប័នរដ្ឋ ទាក់ទងនឹងការមិនរើសអើងលើស្ត្រី។ បើទោះជាក្រសួងកិច្ចការនារីបានបង្ហាញថា ជាក់ស្តែង ខ្លួនបានធ្វើការត្រួតពិនិត្យលើកិច្ចខិតខំប្រឹងប្រែងនានាក៏ដោយ ក៏នេះគ្រាន់តែជាគោលនយោបាយដែលមិនសូវមានប្រសិទ្ធភាពពិតប្រាកដនោះទេ ពីព្រោះថា

បើគ្រាន់តែជាការត្រួតពិនិត្យធម្មតាៗទៅលើសកម្មភាព ដោយមិនបានចែង និងអនុវត្តវិធានការផ្សេងៗនៅក្នុងគោលនយោបាយ ដើម្បីបញ្ឈប់ការរើសអើងនេះទេ នោះគឺជារឿងដែលមិនសូវមានន័យ។

បើទោះជា អនុសញ្ញាស៊ី ដវ មិនតម្រូវឲ្យមានការគិតគូរ ឬការពិភាក្សា អំពីស្ត្រីជនជាតិដើមភាគតិចដាច់ដោយឡែកនៅក្នុងរបាយការណ៍របស់រដ្ឋភាគីក៏ដោយ យើងបានកត់សម្គាល់ឃើញថា កាតព្វកិច្ចក្នុងការលុបបំបាត់ការរើសអើងលើស្ត្រីភេទ បានស្នើឲ្យមានការពិភាក្សាមួយចំពោះតែស្ត្រីនៅទីជនបទ និងស្ត្រីនៅតំបន់ឆ្ងាយ ប៉ុន្តែមិនបានស្នើឲ្យមានការពិភាក្សាណាមួយដែលផ្តោតទៅលើស្ត្រីជនជាតិដើមភាគតិចនោះឡើយ។ តាមការប៉ាន់ប្រមាណ មានចំនួនប្រជាជនភាគតិចប្រហែល ១ភាគរយ (ចន្លោះ ៥៥.០០០ និង ៧៥.០០០ នាក់ជាស្ត្រី) ហើយយើងត្រូវបានស្នើសុំឲ្យទទួលស្គាល់ សិទ្ធិសម្ងហាភាពរបស់ស្ត្រីជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា និងទទួលស្គាល់ថា មានការរើសអើងមកលើពួកគាត់មែន។

## មាត្រា ៣ និង ៤៖ ការអភិវឌ្ឍន៍ និងវឌ្ឍនភាពរបស់ស្ត្រី ការពន្លឿនឲ្យមានសមភាពរវាងបុរស និងស្ត្រី

រាជរដ្ឋាភិបាលកម្ពុជាបានលើកឡើងនូវវិធានការផ្សេងៗជាច្រើន ដែលខ្លួនបានអនុវត្តកន្លងមក ក្នុងការពន្លឿនឲ្យមានសមភាពរបស់ស្ត្រីក្នុងជួររដ្ឋាភិបាល ដោយរួមមាន ការបង្កើតចំនួនកូតាផ្សេងៗដល់បេក្ខជនជាស្ត្រី សម្រាប់តួនាទីនៅក្នុងក្រសួងនានា។ រាជរដ្ឋាភិបាលបានតែងតាំងស្ត្រីចំនួន ២៤ នាក់ សម្រាប់មុខតំណែងជាអភិបាលរងខេត្ត-ក្រុង ក្នុងឆ្នាំ២០០៩ និងបានតែងតាំងស្ត្រីចំនួន ១៨៧នាក់ សម្រាប់មុខតំណែង ជាអភិបាលរងខេត្ត-ក្រុង និងអភិបាលរងស្រុក-ខណ្ឌ។

បច្ចុប្បន្ននេះ មានស្ត្រីមួយចំនួន កាន់តួនាទីនៅក្នុងជួររដ្ឋាភិបាល រួមមាន ឧបនាយករដ្ឋមន្ត្រីម្នាក់ (ក្នុងចំណោម ៩ នាក់) រដ្ឋមន្ត្រី ២ នាក់ (រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងរដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ~ ព្រឹទ្ធសភា និងអធិការកិច្ច) រដ្ឋលេខាធិការចំនួន ១៤ នាក់ និងអនុរដ្ឋលេខាធិការចំនួន ២៩ នាក់។

មន្ត្រីរាជការជាស្ត្រីមានចំនួនប្រមាណ ២០ ភាគរយ នៃមន្ត្រីរាជការសរុប។ រាជរដ្ឋាភិ

បាលកម្ពុជាបានកំណត់គោលដៅឲ្យបាន ៥០ ភាគរយនៃចំនួនមន្ត្រីរាជការជាស្ត្រី ប៉ុន្តែបានអះអាងថា ដោយសារកង្វះចំនួនស្ត្រីដែលមានការអប់រំគ្រប់គ្រាន់ ធ្វើឲ្យមានការលំបាកក្នុងការសម្រេចគោលដៅ។ ប្រការនេះ បានបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់នូវភាពចាំបាច់របស់រាជរដ្ឋាភិបាលក្នុងការផ្តល់ការអប់រំកម្រិតខ្ពស់ដល់ស្ត្រី។ បន្ទាប់ពីការបោះឆ្នោតខែកក្កដា ឆ្នាំ ២០១៣ សមាជិកសភាជាស្ត្រី មានចំនួន ២៥ នាក់ ចំនួននេះមានការថយចុះបន្តិច បើប្រៀបធៀបនឹងអាណត្តិមុន។

គួរកត់សម្គាល់ផងដែរថា ក្នុងរបាយការណ៍ជាតិ រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តដាក់តែទៅលើការឈប់សម្រាកលំហែលមាតុភាព និងសេវារបស់រដ្ឋាភិបាលតែប៉ុណ្ណោះ ប៉ុន្តែមិនបានផ្តោតការយកចិត្តដាក់ទៅលើវិធានការទប់ស្កាត់ការរើសអើង នៅក្នុងវិស័យអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងជំនាញជាន់ខ្ពស់ ការងារ និងកត្តាវប្បធម៌ផ្សេងៗ ហេតុដូច្នេះហើយ បានជាវិសមភាពនៅតែបន្តកើតមានក្នុងវិស័យទាំងនេះ។

## មាត្រា ៥៖ តួនាទីភេទ និងផ្នត់គំនិត

រាជរដ្ឋាភិបាលកម្ពុជាលើកឡើងថា "ស្ត្រីអាចមានឯករាជ្យភាព និងការគ្រប់គ្រងលើខ្លួនឯង ហើយថា ស្ត្រីគួរតែជាម្ចាស់ និងជាអ្នកចាត់ចែងដីធ្លី និងប្រាក់កាក់ និងមានសមត្ថភាពពេញលេញក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងគ្រួសារ។ ជាទូទៅ ស្ត្រីមានអំណាចតិចជាងបុរស លើការចាយវាយ ការងារ និងការសម្រេចចិត្តនៅក្នុងគ្រួសារ។ វប្បធម៌កម្ពុជាបានបង្ហាញនូវការទុកចិត្តទៅលើសមត្ថភាពរបស់បុរស ក្នុងការទទួលខុសត្រូវលើហិរញ្ញវត្ថុរបស់គ្រួសារ និងការសម្រេចចិត្តផ្សេងៗ ខណៈដែលស្ត្រីត្រូវបានគេយល់ថា មិនមានសមត្ថភាពពេញលេញក្នុងការបំពេញកិច្ចការទាំងអស់នេះទេ។

ស្ត្រីនៅតែត្រូវបានគេរារាំងមិនឲ្យកាន់កាប់ដីធ្លីដោយប្រើប្រាស់ឈ្មោះរបស់ខ្លួនដោយសេរី និងច្បាស់លាស់។ ជាធម្មតា ស្ត្រីអាចកាន់កាប់ដីធ្លីបាន ទាល់តែមានការយល់ព្រមពីស្វាមីរបស់ខ្លួន។ ស្ត្រីភាគច្រើនលើសលុបត្រូវបានសង្គមយល់ថា មិនមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការចាត់ចែងមុខជំនួញ ឬ លុយកាក់ក្នុងទ្រង់ទ្រាយធំនោះទេ។

ច្បាប់ស្រីដែលជាក្រមសីលធម៌សម្រាប់ស្ត្រី គឺជាច្បាប់ប្រពៃណី ដែលមានតាំងពីសតវត្សទី១៩ មកម្ល៉េះ។ កាលពីមុន ច្បាប់នេះបានបញ្ចូលទៅក្នុងកម្មវិធីអប់រំនៅថ្នាក់បឋមសិក្សា ហើយបានចាក់ឫសយ៉ាងជ្រៅនៅក្នុងវប្បធម៌កម្ពុជា ច្បាប់នេះកំណត់យ៉ាងច្បាស់នូវភារកិច្ច និងការរំពឹងទុកទៅលើឥរិយាបថរបស់ស្ត្រី។ បើទោះជាច្បាប់ស្រីនេះមិនមាននៅក្នុងកម្មវិធីសិក្សាទៀតក៏ដោយ ក៏មនោគមវិជ្ជាដែលបង្កើតដោយច្បាប់នេះ នៅតែមានឥទ្ធិពលនៅក្នុងសង្គមខ្មែរ ជាពិសេសនៅទីជនបទ។

## មាត្រា ៦៖ ការធ្វើអាជីវកម្មលើស្ត្រី

បើទោះជាមានការបង្កើតនូវអង្គភាពពិសេសប្រឆាំងបទល្មើសផ្លូវភេទ ភ្នាក់ងារឃ្លាំមើល និងក្រុមកិច្ចការពិសេសក៏ដោយ ក៏បញ្ហាជួញដូរមនុស្ស និងជួញដូរផ្លូវភេទ និងបញ្ហាផ្សេងទៀតដែលទាក់ទងនឹងការជួញដូរផ្លូវភេទ ដូចជា ការរំលោភសេពសន្ថវៈ អំពើហិង្សាលើស្ត្រី បញ្ហាជម្ងឺ និងបញ្ហាញៀនស្រា នៅតែមានសភាពធ្ងន់ធ្ងរ។ តាមការប៉ាន់ប្រមាណ ស្ត្រីប្រកបរបរផ្លូវភេទមាន ចំនួនចន្លោះពី ១៤.៧២៥ ទៅ ១៨.២៥០ នាក់។ ទេសចរណ៍ផ្លូវភេទក៏ជាបញ្ហាមួយផងដែរ ដែលបណ្តាលមកពីភាពក្រីក្រ និងនិទណ្ឌភាព។ របាយការណ៍ខ្លះបានបង្ហាញថា មានចំនួនករណីជួញដូរផ្លូវភេទ ការរំលោភសេពសន្ថវៈ និងការប៉ុនប៉ងរំលោភសេពសន្ថវៈ បានកើនឡើងក្នុងឆ្នាំ ២០១២ បើប្រៀបធៀបនឹងឆ្នាំ ២០១១។ បញ្ហានេះបានឆ្លុះបញ្ចាំងឲ្យឃើញ តាមរយៈការទំលាក់ចំណាត់ថ្នាក់ពីលំដាប់ទី 2 (Tier 2) ទៅលំដាប់ថ្នាក់លេខ២ ដែលត្រូវឃ្លាំមើល (Tier 2 Watch List) នៅក្នុងរបាយការណ៍ ឆ្នាំ ២០១៣ ស្តីពីការជួញដូរមនុស្សរបស់ក្រសួងការបរទេស សហរដ្ឋអាមេរិក ពីព្រោះកិច្ចខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ត្រូវបានគេរាយការណ៍ថា មានការធ្លាក់ចុះជាងឆ្នាំមុន។

ចាប់តាំងពីការធ្វើពេស្យាកម្មត្រូវបានចាត់ជាសកម្មភាពខុសច្បាប់ នារីប្រកបរបរផ្លូវភេទជាច្រើន បានធ្វើកិច្ចការនេះដោយលួចលាក់ ដែលធ្វើឲ្យមានការលំបាកដល់ការអនុវត្តកម្មវិធីមួយចំនួន ដែលត្រូវធ្វើការផ្ទាល់ជាមួយអ្នកទាំងនោះ។ មានរបាយការណ៍ជាច្រើនរាយការណ៍អំពីអំពើពុករលួយរបស់មន្ត្រីនគរបាល ដែលទទួលបានផលប្រយោជន៍ផ្ទាល់ពីការជួញដូរផ្លូវភេទ។ នារីប្រកបរបរផ្លូវភេទ ក៏ជាជនរងគ្រោះនៃការរំលោភបំពានលើរាងកាយ និងផ្លូវភេទ ពីសំណាក់មន្ត្រីនគរបាលផងដែរ។

យោងតាមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០០៨ មេបនត្រូវទទួលទោសធ្ងន់ជាងនារីប្រកបរបរផ្លូវភេទ។ ជនប្រព្រឹត្តអំពើជួញដូរផ្លូវភេទ បានប្រើប្រាស់បក្សពួករបស់ខ្លួន និងសំណូក ដើម្បីគេចផុតពីការផ្តន្ទាទោស។ ក្នុងឆ្នាំ២០១២ មានត្រឹមតែ ២៣ ភាគរយប៉ុណ្ណោះ ក្នុងចំណោមជនជាប់ចោទពីការប្រព្រឹត្តអំពើជួញដូរផ្លូវភេទ ត្រូវបានចាប់ខ្លួន។ មេបនមានលុយកាក់គ្រប់គ្រាន់ ដើម្បីជួលមេធាវីឯកជន ប៉ុន្តែជនរងគ្រោះ ត្រូវពឹងផ្អែកលើមេធាវីរបស់អង្គការមិនមែនរដ្ឋាភិបាល សម្រាប់ជំនួយផ្នែកច្បាប់។ សមត្ថភាព ខាងផ្នែកច្បាប់ទាំងអស់នៅប្រទេសកម្ពុជា ចំនួនមេធាវីមានតិចជាង ៨០០ នាក់ ដែលចំនួន នេះរាប់ទាំងវិស័យឯកជន និងវិស័យសាធារណៈ។ លទ្ធផលកើតចេញពីគោលនយោបាយទី ក្រុងស្អាត (Phnom Penh Clean City Policy) និងច្បាប់ជួញដូរ ធ្វើឲ្យនារីប្រកបរបរផ្លូវភេទ ជួប ការលំបាកក្នុងការ ការពារខ្លួនរបស់ពួកគាត់ពីមេរោគអេដស៍/ជម្ងឺអេដស៍ ពីព្រោះ ប្រសិនបើ មន្ត្រីនគរបាលឃើញពួកគាត់មានស្រោមអនាម័យ នោះពួកគាត់ទំនងជាប្រឈមនឹងការចាប់ ខ្លួន។ នារីប្រកបរបរផ្លូវភេទក៏មិនបានតម្រូវឲ្យធ្វើតេសរកជម្ងឺឆ្លងនោះដែរ។ ដោយសារមានការ កើនឡើងនាពេលថ្មីនេះនូវចំនួនមន្ទីរពេទ្យដែលត្រូវបានប្តូរទៅជាមន្ទីរពេទ្យឯកជន ធ្វើឲ្យនារី ប្រកបរបរផ្លូវភេទជាច្រើន លែងមានលទ្ធភាពបង់ថ្លៃសេវាថែទាំសុខភាព។ នារីប្រកបរបរផ្លូវ ភេទ ក៏រងនូវការរើសអើងនៅមន្ទីរពេទ្យ និងមណ្ឌលសុខភាពផងដែរ។ អំពើហិង្សាលើនារី ប្រកបរបរផ្លូវភេទ មានការរីករាលដាល ហើយការកើនឡើងដែលគួរឲ្យបារម្ភនោះ គឺការ រំលោភបូក។ ស្រោមអនាម័យមានតម្លៃថ្លៃ ហើយនារីប្រកបរបរផ្លូវភេទមិនអាចរកទិញស្រោម អនាម័យគ្រប់ពេលនោះទេ។ ស្ត្រីដែលមានបំណងដកខ្លួនចេញពីរបរផ្លូវភេទ ជួបការលំបាក ដោយសារតែរាជរដ្ឋាភិបាលផ្តល់នូវកម្មវិធីស្តារលទ្ធភាពឡើងមានចំនួនតិចតួចប៉ុណ្ណោះ។ ជា រឿយៗ អតីតនារីប្រកបរបរផ្លូវភេទ ប្រឈមនឹងការប្រមាថពីសង្គម (Stigma) ហើយកង្វះនូវ ការទទួលស្គាល់ និងការគាំទ្រ ទាំងនេះជាកត្តាជម្រុញឲ្យពួកគាត់ត្រឡប់ទៅប្រកបរបរផ្លូវ ភេទវិញ។ កម្ពុជាក៏ទទួលបាននាមជាឋានសួគ៌សម្រាប់អ្នកស្វែងរកសេវាផ្លូវភេទ និង មនុស្ស ដែលមានចំណង់ផ្លូវភេទជាមួយកុមារ ជនទាំងនេះឆ្លៀតឱកាសកេងចំណេញពេញទំហឹងពី ភាពមិនច្បាស់លាស់នៃការបកស្រាយច្បាប់ និងកង្វះនូវការអនុវត្តន៍ច្បាប់។

## មាត្រា៧៖ ជីវិភាពនយោបាយ និងសង្គម

រាជរដ្ឋាភិបាលកម្ពុជាពិតជាបានចាត់វិធានជាវិជ្ជមានមួយចំនួន ដើម្បីបង្កើនចំនួនស្ត្រី ក្នុងតួនាទីជាថ្នាក់ដឹកនាំស្ថាប័នរដ្ឋ ឧទាហរណ៍ដូចជា ការដាក់កំណត់ឲ្យមានស្ត្រីយ៉ាងតិច

ណាស់ម្នាក់ ជាអភិបាលរង នៅគ្រប់ខេត្ត-ក្រុង ស្រុកខណ្ឌ។ ក្នុងការបោះឆ្នោតឆ្នាំ ២០១២ បេក្ខជនជាស្ត្រីមានត្រឹមតែ ២៥.៦៤ ភាគរយប៉ុណ្ណោះ។ តាមការប៉ាន់ប្រមាណ មានបេក្ខជនជាស្ត្រីចំនួន ២០,៣២ ភាគរយប៉ុណ្ណោះ បានជាប់ឆ្នោត។

រាជរដ្ឋាភិបានបានលើកឡើងនូវបញ្ញត្តិធម្មនុញ្ញបន្ថែម ដែលរាជរដ្ឋាភិបាលនិយាយថា បញ្ញត្តិធម្មនុញ្ញបន្ថែមនេះ ជួយសម្របសម្រួលដល់លទ្ធភាពរបស់ស្ត្រី ក្នុងការចូលរួមដោយស្មើភាពនៅក្នុងឆាកនយោបាយ ឧទាហរណ៍ដូចជា លើកឡើងនូវបញ្ញត្តិដែលចែងថា ពលរដ្ឋខ្មែរទាំងពីរភេទមាន សិទ្ធិបោះឆ្នោត នៅពេលមានអាយុគ្រប់១៨ ឆ្នាំ ឬឈរឈ្មោះឲ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ប្រសិនបើពួកគេមានអាយុយ៉ាងតិច ២៥ ឆ្នាំ ឬក៏ឈរឈ្មោះឲ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា ប្រសិនបើពួកគេមានអាយុយ៉ាងតិច ៤០ ឆ្នាំ។ ទោះបីជា មានបញ្ញត្តិទាំងនេះក៏ដោយ ក៏ស្ត្រីជាច្រើនដែលមានសិទ្ធិបោះឆ្នោត ត្រូវបានគេដកសិទ្ធិមិនឲ្យបោះឆ្នោត។ ស្ត្រីដែលទទួលរងការបណ្តេញចេញពីដីធ្លីដោយបង្ខំ ធ្វើឲ្យសិទ្ធិបោះឆ្នោតរបស់អ្នកទាំងនេះត្រូវបានដកចេញ បញ្ហានេះគឺបណ្តាលមកពីការបណ្តេញចេញដោយបង្ខំ និងការគ្មានលំនៅស្ថាន។ ការស្រាវជ្រាវ បង្ហាញថា ស្ត្រីជាច្រើនត្រូវបានបណ្តេញចេញពីការងារ ជាពិសេស នៅក្នុងឧស្សាហកម្មកាត់ដេរ នៅពេលដែលពួកគាត់ចូលរួមជាមួយសហជីពការងារ។ ច្បាប់ស្តីពីការចូលរួមរបស់ស្ត្រី នៅក្នុងសមាគម និងអង្គការឯកជនផ្សេងៗ ជារឿយៗ មិនត្រូវបានយកមកអនុវត្តដោយភាគីនយោជកនោះឡើយ នេះមានន័យថា បញ្ញត្តិធម្មនុញ្ញបន្ថែមទាំងនេះមិនទទួលបានជោគជ័យ ក្នុងការលុបបំបាត់ទម្រង់រើសអើងលើស្ត្រីភេទនោះទេ។

ស្ត្រីត្រូវបានជ្រើសតាំង ដើម្បីបំពេញកូតារបស់រដ្ឋាភិបាល ប៉ុន្តែទោះជាយ៉ាងណា ក្នុងការអនុវត្តជាក់ស្តែង អ្នកទាំងនេះគ្រាន់តែមាននាមជាថ្នាក់ដឹកនាំ តែមិនសូវមានសិទ្ធិអំណាចនោះទេ។ ជាធម្មតា ក្នុងអំឡុងពេលបោះឆ្នោត គណបក្សនយោបាយតែងតែដាក់បេក្ខជនជាស្ត្រីនៅលំដាប់លេខរៀងខាងក្រោមបំផុតនៃបញ្ជីរាយនាមបេក្ខជន ដើម្បីធានាថាបេក្ខជនជាស្ត្រីទាំងនេះ មិនត្រូវបានជ្រើសតាំងឲ្យកាន់តួនាទីដែលមានអំណាច។ ក្នុងការបោះឆ្នោតឃុំ-សង្កាត់ចុងក្រោយកន្លងមក មានបេក្ខជនជាស្ត្រីឈរឈ្មោះចំនួន ២៥,៦៤ ភាគរយ តែមានបេក្ខជនជាស្ត្រីចំនួន ១៧,៧៨ ភាគរយប៉ុណ្ណោះ បានជាប់ឆ្នោត។

រាជរដ្ឋាភិបាលកម្ពុជាបានបែកចែកថវិកាជាតិត្រឹមតែប្រមាណ ០,៦៦ ភាគរយ នៃថវិកាជាតិសរុបប៉ុណ្ណោះ សម្រាប់កិច្ចការស្ត្រី។

## មាត្រា៩៖ សញ្ជាតិ

រាជរដ្ឋាភិបាលកម្ពុជាមិនបានដោះស្រាយបញ្ហាលំបាក ដែលស្ត្រីជនជាតិភាគតិចជួបប្រទះ ក្នុងការទទួលបានសញ្ជាតិនោះទេ ក្នុងនោះ ស្ត្រីកម្ពុជាក្រោមជាអ្នកងាយរងគ្រោះយ៉ាងខ្លាំង ទាក់ទងនឹងបញ្ហាសញ្ជាតិនេះ។ មានការរឹតត្បិតយ៉ាងតឹងតែងផងដែរលើការបោះឆ្នោត ចំពោះប្រជាពលរដ្ឋខ្មែរដែលរស់នៅបរទេស ដើម្បីបានចូលរួមបោះឆ្នោត អ្នកទាំងនេះត្រូវត្រលប់មកកម្ពុជាពីរដង ម្តងដើម្បីចុះឈ្មោះ និងម្តងទៀតដើម្បីបោះឆ្នោត។ ការរឹតត្បិតបែបនេះ ប៉ះពាល់ដល់ប្រជាពលរដ្ឋខ្មែរជាង ១ លាន នាក់។

យោងតាមច្បាប់ ស្ត្រីទោះរៀបការរួច ឬ មិនទាន់រៀបការក៏ដោយ ក៏មានសិទ្ធិស្មើនឹងបុរស ក្នុងការទទួលបាន ផ្លាស់ប្តូរ ឬរក្សាទុកសញ្ជាតិរបស់ខ្លួនដែរ។ ក្នុងការអនុវត្តជាក់ស្តែងដោយសារតែអំពើពុករលួយ នៅតែមានការរើសអើងទៅលើយេនឌ័រ ទាក់ទងនឹងបញ្ហាសញ្ជាតិនេះ។ ជាទូទៅ បុរសដែលមិនមែនជាសញ្ជាតិខ្មែរ មានភាពងាយស្រួលជាងស្ត្រី ក្នុងទទួលបានសញ្ជាតិនៅកម្ពុជា។

រយៈពេលកន្លងមក សេចក្តីបង្គាប់ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល មានអនុភាពបង្កឲ្យមានការរើសអើងដោយប្រយោលទៅលើស្ត្រីខ្មែរ ដែលរៀបការជាមួយបុរសជនជាតិបរទេស រួមមានសេចក្តីបង្គាប់មួយ ដែលហាមឃាត់មិនឲ្យស្ត្រីខ្មែររៀបការជាមួយបុរសជនជាតិបរទេស ដែលមានសញ្ជាតិមួយចំនួន លក្ខខណ្ឌអាយុ និងប្រាក់ចំណូល។ ជារឿយៗ ស្ត្រីខ្មែរ រៀបការជាមួយបុរសជនជាតិបរទេសតាមលក្ខណៈប្រពៃណី ដោយមិនមានឯកសារបញ្ជាក់ពីអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ដែលធ្វើឲ្យស្ត្រីខ្មែរទាំងនោះ មិនមានសិទ្ធិជាប្រពន្ធស្របច្បាប់។

## មាត្រា ១០៖ ការអប់រំ

ឧបសគ្គ និងការអនុវត្តន៍មួយចំនួនទាក់ទងនឹងកត្តាវប្បធម៌ សង្គម និងសេដ្ឋកិច្ច នៅកម្ពុជា កំពុងបណ្តាលឲ្យមានគំលាតកាន់តែខ្លាំង ចំពោះឱកាសក្នុងការទទួលបានការសិក្សាអប់រំរបស់ស្ត្រី និងកុមារី ដែលធ្វើឲ្យអ្នកទាំងនេះកាន់តែបាត់បង់ឱកាសខ្លាំងឡើង។

យោងតាមរបាយការណ៍ ដែលមានចំណងជើងថា "ការលើកកម្ពស់សិទ្ធិនៅក្នុងសាលារៀន "អត្រាចុះឈ្មោះចូលរៀន មានការកើនឡើងចន្លោះឆ្នាំ ២០០៥ និង ២០១២ ពី ៩១,៣ ភាគរយ ទៅ ៩៦,៤ ភាគរយ។ ទោះជាយ៉ាងណា មិនមានការបញ្ជាក់ពីវត្តមាននៃការចូលរៀនរបស់សិស្សនោះឡើយ។ អត្រាបោះបង់ចោលការសិក្សារបស់សិស្សស្រី មានអត្រាខ្ពស់ជាងសិស្សប្រុស។ គ្រួសារជាច្រើនផ្តោតការយកចិត្តទុកដាក់លើការសិក្សារបស់កូនប្រុសច្រើនជាងកូនស្រី ជាពិសេស គ្រួសារដែលមានប្រាក់ចំណូលទាប។ ពេលស្ត្រីមានផ្ទៃពោះ ឬរៀបការ អ្នកទាំងនេះត្រូវបោះបង់ចោលការសិក្សា។ នៅទីជនបទ នៅក្នុងភូមិមានតែសាលាកម្រិតបឋមសិក្សាតែប៉ុណ្ណោះ កត្តានេះបង្ខំឲ្យអ្នកដែលចង់បន្តការសិក្សាកម្រិតខ្ពស់ ត្រូវធ្វើដំណើរទៅនៅទីក្រុង។ សិស្សប្រុសអាចស្នាក់នៅវត្តដោយមិនអស់ប្រាក់កាស ប៉ុន្តែសិស្សនារីមិនមានឱកាសបែបនេះទេ។ ជាងនេះទៅទៀត ឪពុកម្តាយបង្ហាញនូវការព្រួយបារម្ភណ៍ចំពោះសុវត្ថិភាពកូនស្រី ដែលត្រូវទៅរស់នៅទីក្រុងតែម្នាក់ឯង។ គុណភាពនៃអប់រំដែលមានសព្វថ្ងៃជាបញ្ហាដ៏ចំបង។ គ្រូភាគច្រើនបានបញ្ចប់ការសិក្សាត្រឹមតែកម្រិតវិទ្យាល័យតែប៉ុណ្ណោះ ហើយប្រាក់បៀវត្សរបស់គ្រូទាំងនេះ ក៏មានកម្រិតទាបផងដែរ។ បើទោះជា សិទ្ធិទទួលបានការអប់រំមានចែងក្នុងរដ្ឋធម្មនុញ្ញ ការរៀនសូត្រមិនមែនឥតគិតថ្លៃនោះទេ ពីព្រោះឪពុកម្តាយត្រូវចំណាយថ្លៃឈ្នួលក្រៅផ្លូវការច្រើន ដើម្បីបញ្ជូនកូនៗទៅសាលារៀន ការចំណាយមួយចំនួនរួមមាន ថ្លៃឈ្នួលគ្រូប្រចាំថ្ងៃ ថ្លៃប្រឡង អំណោយសម្រាប់គ្រូ និងថ្លៃរៀនគួរបន្ថែម។ កម្មវិធីផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ បានជួយឲ្យមានការកើនឡើងចំនួនស្ត្រី និងកុមារី ក្នុងការបន្តការសិក្សាកម្រិតឧត្តមសិក្សា ប៉ុន្តែ ចំនួននិស្សិតស្រីក្នុងចំណោមចំនួននិស្សិតនៅកម្រិតឧត្តមសិក្សា នៅតែមានចំនួនតិចតួចណាស់។ កម្មវិធីផ្តល់អាហារូបករណ៍របស់រាជរដ្ឋាភិបាលកម្ពុជា នៅមានចំនួនមិនគ្រប់គ្រាន់ទៅតាមបរិមាណ និងវិសាលភាពរបស់កម្មវិធីនោះទេ។

## មាត្រា១១៖ ការងារ

ដោយសារមានវិសមភាពយ៉ាងធំក្នុងការសិក្សាអប់រំរវាងយេនឌ័រ ធ្វើឲ្យស្ត្រីមិនទទួលបានសិទ្ធិស្មើភាពគ្នាក្នុងការងារនោះទេ។ ក្នុងករណី ស្ត្រីមានការអប់រំ និងជំនាញខ្ពស់ជាង

បុរសដែលមានតំណែងស្មើគ្នា ស្ត្រីត្រូវបានគេជ្រើសរើសឲ្យធ្វើការជាងបុរស នេះបង្ហាញពីសារៈសំខាន់នៃការបណ្ដាក់ទុនទៅលើការអប់រំ និងការបណ្ដុះបណ្ដាលដែលមានគុណភាពកាន់តែប្រសើរសម្រាប់ស្ត្រី ដែលនេះ គឺជាកត្តាអាចជំរុញឲ្យមានភាពស្មើគ្នារវាងបុរស និងស្ត្រីដ៏មានសក្ដានុពលមួយ នៅក្នុងសន្ទុះនៃកម្លាំងការងាររបស់ប្រទេសកម្ពុជា។

យោងតាមរាជរដ្ឋាភិបាលកម្ពុជា ដែលបានធ្វើការសិក្សាស្រាវជ្រាវលើគ្រឹះស្ថានចំនួន ១.២៧៣ បានរកឃើញថា ចំនួនកម្មករភាគច្រើន គឺជាស្ត្រី នេះមិនមានន័យថា ស្ត្រីទាំងនេះមានភាពស្មើគ្នាក្នុងការងារនោះទេ ប្រសិនបើពួកគាត់មិនមានឱកាសក្លាយជា អ្នកគ្រប់គ្រង ឬបុគ្គលិកដែលមានតំណែងកាន់តែប្រសើរ និងប្រសិនបើ អ្នកទាំងនេះប្រឈមនឹងលក្ខខណ្ឌការងារមិនល្អ ដែលបញ្ហានេះ ត្រូវគេដឹងថា តែងតែកើតមាននៅកន្លែងការងារភាគច្រើន។

ចំនួនភាគរយនៃស្ត្រីនៅក្នុងកម្លាំងការងារស្មើតែស្មើនឹងបុរស គឺមាន៤៩,៤ ភាគរយ។ យោងតាមច្បាប់ការងារ ស្ត្រីត្រូវបានធានានូវការទទួលបានប្រាក់ឈ្នួលស្មើគ្នា ចំពោះការងារដូចគ្នា។ ទោះជាយ៉ាងណា ការកំណត់ប្រាក់ឈ្នួលមានភាពខុសគ្នារវាងបុរស និងស្ត្រី។

ច្បាប់ស្ដីពីរបបសន្តិសុខសង្គម សំរាប់បុគ្គលទាំងឡាយណាដែលត្រូវបានកំណត់ក្នុងច្បាប់ការងារ ក៏បានធានានូវសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រីផងដែរ ក្នុងការទទួលបានអត្ថប្រយោជន៍ផ្សេងៗពីរបបសន្តិសុខសង្គម ។ មូលនិធិសន្តិសុខសង្គម ធានានូវការអនុវត្តន៍បញ្ញត្តិនៃច្បាប់ស្ដីពីរបបសន្តិសង្គម ត្រូវអនុលោមទៅតាមច្បាប់ការងារ ប៉ុន្តែ ប្រសិទ្ធភាពការងារគឺតិចតួចណាស់។ យោងតាមអង្គការពលកម្មអន្តរជាតិ(ILO) ស្ត្រីមេម៉ាយ នៅបន្តទទួលបានអត្ថប្រយោជន៍ពីរបបសន្តិសុខសង្គម។ ទោះជាយ៉ាងណា ចំនួនដែលផ្ដល់ឲ្យ គឺមិនគ្រប់គ្រាន់សម្រាប់ការរស់នៅនោះទេ ត្រឹមតែចំនួន ១,៥ ដុល្លារ ក្នុងមួយខែ សម្រាប់ស្ត្រី មេមាយ និង១,២៥ ដុល្លារ ក្នុងមួយខែ សម្រាប់កូនម្នាក់ ស្ថិតក្រោមអាយុ ១៦ ឆ្នាំ។

ក្រៅពីអត្ថប្រយោជន៍ដែលទទួលបានពីរបបសន្តិសុខសង្គម ច្បាប់ការងារក៏ផ្ដល់សិទ្ធិដល់ស្ត្រី ឲ្យទទួលបានការឈប់សម្រាកលំហែមាតុភាព ចំនួន ៩០ ថ្ងៃ (មាត្រា ១៦៩)។ ទោះជាយ៉ាងណា នៅក្នុងវិស័យឧស្សាហកម្មជាច្រើន ស្ត្រីត្រូវគេបណ្ដេញចេញពីការងារ នៅពេលដែលអ្នកទាំងនេះមានផ្ទៃពោះពី៥-៦ ខែ ដើម្បីរួចផុតពីការចំណាយប្រាក់ឈ្នួលទៅលើការឈប់សម្រាកលំហែមាតុភាព។ បើទោះជា រាជរដ្ឋាភិបាលបានលើកឡើងថា វិស័យកាត់

ដេរ ជាវិស័យដែលមានស្ត្រីធ្វើការច្រើនជាងគេ ប៉ុន្តែរាជរដ្ឋាភិបាលមិនបានដោះស្រាយចំពោះការរំលោភសិទ្ធិសំខាន់ៗ និង ការធ្លាក់ចុះនៃតម្លៃរបស់មនុស្សជាបន្តបន្ទាប់ ដែលកំពុងកើតមាននៅក្នុងរោងចក្រកាត់ដេរជាច្រើននោះទេ។ មានរោងចក្រកាត់ដេរយ៉ាងតិចចំនួន ៥៥៨ ដែលផ្តល់ការងារឲ្យកម្មករជាង ៤០០.០០០ នាក់ ហើយមានកម្មករជាស្ត្រីចំនួន ៩០ ភាគរយនៃចំនួនកម្មករសរុបនៅក្នុងវិស័យនេះ។ បញ្ហាមួយក្នុងចំណោមបញ្ហាផ្សេងទៀត គឺស្ត្រីជាកម្មកររោងចក្រកាត់ដេរ មិនទទួលបានប្រាក់ឈ្នួលអប្បបរិមា ហើយត្រូវបង្ខំឲ្យធ្វើការបន្ថែមម៉ោងដែលលក្ខខណ្ឌការងារនៅក្នុងរោងចក្រទាំងនោះត្រូវគេដឹងថា មានកម្រិតទាប។

មានការរំលោភបំពានកម្លាំងពលកម្មដ៏ធ្ងន់ធ្ងរផងដែរ ទៅលើកម្មករចំណាកស្រុក។ ជារឿយៗ កម្មករចំណាកស្រុក ប្រឈមនឹងប្រាក់ឈ្នួលទាប ធ្វើការច្រើនម៉ោង អាហារមិនគ្រប់គ្រាន់ រងការប្រព្រឹត្តមិនល្អ ការធ្វើទារុណកម្ម គ្មានសេវាថែទាំសុខភាព និងមិនទទួលបានការការពារផ្នែកច្បាប់។

ស្ត្រីប្រកបរបរផ្លូវភេទប្រឈមនឹងការចាប់ខ្លួន ប្រសិនបើអាជ្ញាធរតាមទាន់អ្នកទាំងនេះ។ ដោយសារកត្តានេះ ស្ត្រីប្រកបរបរផ្លូវភេទភាគច្រើន ត្រូវធ្វើការលាក់ខ្លួន ធ្វើឲ្យកម្មវិធីចុះជួបផ្ទាល់ជាមួយពួកគាត់ ពិបាកអនុវត្ត។ ស្ត្រីធ្វើការនៅក្នុងសេវាកម្មផ្លូវភេទ មិនទទួលបានសិទ្ធិ និងការគាំទ្រគ្រប់គ្រាន់តាមច្បាប់ទេ។ មានការរើសអើងផងដែរទៅលើស្ត្រីដែលធ្វើការជានារីផ្សព្វផ្សាយស្រាបៀ និងធ្វើការនៅក្នុងក្លឹបការ៉ាអូខេ ជាទូទៅ អ្នកទាំងនេះទទួលរងការរំលោភបំពាន និងការធ្វើពេស្យាចារដោយបង្ខំ។

ស្ត្រីភាគច្រើនដែលធ្វើការនៅក្នុងវិស័យការងារក្រៅប្រព័ន្ធ ដូចជា ការងារតាមផ្ទះ កសិកម្ម នេសាទ ព្រៃឈើ និងសហគ្រាសខ្នាតតូច ដែលអ្នកទាំងនេះមិនត្រូវបានការពារដោយច្បាប់ការងារទេ។ យោងតាមអង្គការពលកម្មអន្តរជាតិ ILO ការងារក្រៅប្រព័ន្ធបានស្រូបយកកម្លាំងពលកម្មចំនួន ៨៥ ភាគរយ។

## មាត្រា ១២៖ ភាពស្មើគ្នាក្នុងការទទួលបានការថែទាំសុខភាព

ការទទួលបានដោយស្មើភាពគ្នានូវសេវាថែទាំសុខភាព និងសេវាពន្យារកំណើតដែលមានគុណភាពគ្រប់គ្រាន់ ត្រូវបានរាំងស្ទះ មួយផ្នែកដោយភាពអសមត្ថភាពរបស់រាជរដ្ឋាភិ

បាលកម្ពុជា ក្នុងការចែកចាយព័ត៌មានឲ្យមានប្រសិទ្ធិភាព អំពីសេវាថែទាំសុខភាព និងសេវាពន្យារកំណើតដល់ស្ត្រី។ ឧទាហរណ៍៖ ព័ត៌មានអំពីជម្ងឺឆ្លងតាមការរួមភេទ (STIs) មិនត្រូវបានផ្សព្វផ្សាយឲ្យបានគ្រប់គ្រាន់ និងទៀងទាត់ដល់ប្រជាពលរដ្ឋនោះទេ ជាពិសេសដល់ស្ត្រី។ កង្វះខាតព័ត៌មាន និងសេវាពន្យារកំណើត នៅតែបន្តជាដើមហេតុមួយ ដែលធ្វើឲ្យមានការព្រួយបារម្ភ។ លើសពីនេះទៅទៀត បុគ្គលិកពេទ្យកម្ពុជា ចាំបាច់ត្រូវធ្វើការពង្រឹងសមត្ថភាពច្រើនបន្ថែមទៀត។ ការរួមផ្សំគ្នានៃបញ្ហា ប្រាក់បៀវត្សទាប និងការទទួលការបណ្តុះបណ្តាលនៅមានកម្រិត ធ្វើឲ្យវិស័យវេជ្ជសាស្ត្រមានគុណភាពទាបនៅកម្ពុជា។

បច្ចុប្បន្ននេះ មិនមានកម្មវិធីពិនិត្យឆ្លុះមើលស្ថានភាពជម្ងឺ ដល់ស្ត្រីប្រហែលចំនួន ១៥០០ នាក់ ដែលមានជម្ងឺមហារីកកស្បូននោះទេ។ មន្ទីរពេទ្យមិនបានផ្តល់នូវការព្យាបាលអ្វីទេ ក្រៅពីការផ្តល់ថ្នាំបំបាត់ការឈឺចាប់ ដល់ស្ត្រីចំនួនជាង ៩០០ នាក់ ដែលចំនួននេះ ត្រូវបានស្លាប់ដោយសារជម្ងឺមហារីកកស្បូនជារៀងរាល់ឆ្នាំ។

ខណៈពេលដែលទទួលស្គាល់ថា រាជរដ្ឋាភិបាលកម្ពុជា គួរទទួលបាននូវការកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការទប់ស្កាត់មិនឲ្យមានការរីករាលដាលមេរោគអេដស៍/ជម្ងឺអេដស៍បន្តទៀត ក៏ដូចជាប្រយុទ្ធប្រឆាំងនឹងការរើសអើងលើអ្នកផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ ប៉ុន្តែមានកត្តាដែលនៅជាការព្រួយបារម្ភនោះគឺថា ស្ត្រីប្រឈមនិងការឆ្លងមេរោគអេដស៍/ជម្ងឺអេដស៍ ដោយសារមិនទទួលបានព័ត៌មានអំពីមេរោគអេដស៍ របៀបការពារខ្លួន របៀបឆ្លង និងរបៀបព្យាបាលឲ្យមានប្រសិទ្ធភាព។ ការយល់ដឹងអំពីមេរោគអេដស៍/ជម្ងឺអេដស៍ នៅមានកម្រិតទាប ពិសេសក្នុងចំណោមស្ត្រីមេផ្ទះទាំងឡាយ ដែលយើងជឿថា ផលវិបាកនេះកើតចេញពីផ្នត់គំនិតយេនឌ័រដែលនៅបន្តរីករាលដាលក្នុងគ្រប់វិស័យ និងកើតចេញពីទំនៀបទំលាប់វប្បធម៌កម្ពុជា។ ការរើសអើងទៅលើអ្នកផ្ទុកមេរោគអេដស៍ នៅតែមានលក្ខណៈទូលំទូលាយ និងខ្លាំងក្លា។ ស្ត្រីមានផ្ទៃពោះ ដែលបានឆ្លងមេរោគអេដស៍/ជម្ងឺអេដស៍ ត្រូវបានគេរាយការណ៍ថា អ្នកទាំងនេះប្រឈមនឹងការរើសអើងពីបុគ្គលិកថែទាំសុខភាព ក្នុងអំឡុងពេលសម្រាលកូន។ ជាក់ស្តែង យោងតាមរបាយការណ៍ស្តីពីភាពអាម៉ាស់ ឆ្នាំ ២០១០ (Stigma Index) (ការទទួលអារម្មណ៍ថា គ្មានការលើកទឹកចិត្ត និងគ្មានការទទួលស្គាល់ពីសង្គម ដោយសារមានជម្ងឺណាមួយ) មានអ្នកផ្ទុកមេរោគជម្ងឺ/ជម្ងឺអេដស៍ ចំនួន ១៤,៣ ភាគរយ បាននិយាយថា ពួកគាត់ត្រូវបានណែនាំឲ្យបញ្ឈប់ការមានផ្ទៃពោះ ដោយសារស្ថានភាពផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍របស់ពួកគាត់។ មនុស្សចាស់នៅក្នុងសហគមន៍ ដែលជាអ្នក

ទទួលខុសត្រូវក្នុងការចិញ្ចឹមបីបាច់កុមារ ដែលបាត់បង់ឪពុកម្តាយដោយសារមេរោគអេដស៍/ជម្ងឺអេដស៍ និងចិញ្ចឹមបីបាច់កុមារមានផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ អ្នកទាំងនេះទទួលបានជំនួយតិចតួច ឬមិនទទួលបានទាល់តែសោះពីរាជរដ្ឋាភិបាល។ ក្នុងពេលកន្លងមក អ្នកទាំងនេះ បានទទួលការឧបត្ថម្ភម្ហូបអាហារ ប៉ុន្តែឥឡូវគឺមិនមាននោះទេ។ បុរស-ស្ត្រី ដែលស្រលាញ់ភេទដូចគ្នា ក៏ដូចជាអ្នកញៀនថ្នាំផងដែរ ប្រឈមនឹងការរើសអើងក្នុងការផ្តល់នូវសេវាថែទាំសុខភាពនានា។ ពិសេសនោះ នៅពេលដែលក្រុមទាំងពីរនេះ បង្ហាញពីប្រវត្តិរបស់ខ្លួន អ្នកទាំងនេះអាចប្រឈមនឹងការចាប់ខ្លួន។

## មាត្រា ១៣៖ ផលប្រយោជន៍សេដ្ឋកិច្ច និងសង្គម

មាត្រានេះ តម្រូវឲ្យរាជរដ្ឋាភិបាល មិនត្រឹមតែលុបបំបាត់នូវការរើសអើងដែលកើតឡើងពីរាជរដ្ឋាភិបាលខ្លួនឯងផ្ទាល់នោះទេ ហើយថែមទាំងចាត់វិធានការនានា ដើម្បីធានាថាតួអង្គនៅក្នុងវិស័យឯកជនផ្សេងៗ ក៏មិនត្រូវមានការរើសអើងលើស្ត្រីភេទផងដែរ។

មិនត្រឹមតែច្បាប់មិនត្រូវបានអនុវត្តប៉ុណ្ណោះទេ ថែមទាំងភាសារក្នុងច្បាប់របស់ប្រទេសកម្ពុជា មានអត្ថន័យស្មើនឹងការដកស្ត្រីចេញពីសិទ្ធិ និងឱកាសស្មើគ្នាដូចបុរសទៀតផង។ ឧទាហរណ៍៖ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ បានចែងថា ស្ត្រីត្រូវតែរងចាំរហូតដល់រយៈពេល ១២០ ថ្ងៃ បន្ទាប់ពីលែងលះ មុនពេលដែលស្ត្រីនោះអាចរៀបការថ្មីបាន ប៉ុន្តែមិនមានរយៈពេលរង់ចាំដូចគ្នាសម្រាប់បុរសនោះទេ។

ទោះបីជាស្ត្រីមានសិទ្ធិលើហរិញ្ញវត្ថុស្មើនឹងបុរសក៏ដោយ ក៏បុរសតែងតែគ្រប់គ្រងលុយកាក់ និងទ្រព្យសម្បត្តិនៅក្នុងគ្រួសារ ដោយមិនឲ្យស្ត្រីចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តនោះឡើយ។

## មាត្រា ១៤៖ ស្ត្រីនៅតាមជនបទ

រាជរដ្ឋាភិបាលកម្ពុជា អះអាងថា "កិច្ចខិតខំប្រឹងប្រែងប្រកបដោយការតាំងចិត្ត" បានបង្កើតឡើង ដើម្បីអភិវឌ្ឍប្រទេសកម្ពុជា ហើយការវិវឌ្ឍន៍នេះ ត្រូវបានធ្វើឡើងនៅគ្រប់វិស័យ

ទាំងអស់ ក្នុងគោលបំណងធ្វើឲ្យមានសមភាពនៃកម្រិតជីវភាពរស់នៅ និងសេវាកម្មផ្សេងៗ រវាងទីជនបទ នឹងទីក្រុង។ ជាការបង្ហាញពីភស្តុតាងនៃ "កិច្ចខិតខំប្រឹងប្រែងប្រកបដោយការតាំងចិត្តនេះ" រាជរដ្ឋាភិបាលកម្ពុជា ផ្តល់នូវឧទាហរណ៍នៃវិធានការដែលបានអនុវត្ត ដើម្បី "លើកកំពស់សមភាពរវាងស្ត្រី និងបុរសនៅតាមតំបន់ជនបទ" និងដើម្បីធ្វើឲ្យប្រសើរឡើងដល់ស្ថានភាពរស់នៅនៅតំបន់ជនបទ។ ឧទាហរណ៍ទាំងនេះ រួមមាន ការសាងសង់ផ្លូវថ្មីភ្ជាប់ពីរាជធានី និងខេត្តនានា ទៅកាន់ទីជនបទ ការស្តារឡើងវិញនូវផ្លូវដែក ការសាងសង់ស្ពាន និងប្រព័ន្ធធារាសាស្ត្រ ព្រមទាំងគំនិតផ្តួចផ្តើមមួយចំនួនផ្សេងទៀត។

តាមលទ្ធផលពិតគឺថា គំនិតផ្តួចផ្តើមនានាដូចបានសង្ខេបខាងលើ ក៏ដូចជាចំនុចផ្សេងទៀត ដែលបានលើកឡើងក្នុងរបាយការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា មានប្រសិទ្ធិភាពតិចតួចក្នុងការធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅជាក់ស្តែងដល់ប្រជាពលរដ្ឋនៅជនបទ ក្នុងការបញ្ចប់ការដណ្តើមយកដីធ្លី និងការបណ្តេញចេញដោយបង្ខំ ឬក្នុងការប្រយុទ្ធប្រឆាំងនឹងផលប៉ះពាល់ដ៏ធ្ងន់ធ្ងរនៃការអនុវត្តសកម្មភាពទាំងនេះ លើប្រជាពលរដ្ឋនៅជនបទ (និងទីប្រជុំជន) ឬក្នុងការលើកកំពស់ពិតប្រាកដនូវសមភាពរវាងស្ត្រី និងបុរស។ បើទោះជា គំនិតផ្តួចផ្តើមនានាដែលបានអនុវត្តកន្លងមក អាចផ្តល់អត្ថប្រយោជន៍សំខាន់ៗ ប៉ុន្តែ នឹងមានលទ្ធផលតិចតួចប៉ុណ្ណោះ ប្រសិនបើមិនមានសាលារៀន សេវាថែទាំសុខភាព និងសេវាកម្មដទៃទៀត ឬឱកាសការងារឲ្យបានគ្រប់គ្រាន់នៅទីជនបទនោះទេ។

រាជរដ្ឋាភិបាលកម្ពុជា អះអាងទទួលស្គាល់នូវតួនាទីសំខាន់របស់ស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ច ដែលមិនទទួលបានប្រាក់កម្រៃ។ ការទទួលស្គាល់នេះ ផ្តល់សារៈសំខាន់តិចតួច ព្រោះថាផលប្រយោជន៍សេដ្ឋកិច្ច និងសង្គម មិនបានដល់កម្មករទាំងនោះទេ។ ស្ត្រីធ្វើការដោយមិនទទួលប្រាក់កម្រៃ មិនទទួលបានសេវាថែទាំសុខភាព សម្រាកលំហែមាតុភាព និងសិទ្ធិជាមូលដ្ឋានដទៃទៀតតាមច្បាប់ការងារ។ រដ្ឋបានសន្យានឹង "លើកម្ពស់ការអភិវឌ្ឍន៍សេដ្ឋកិច្ចលើគ្រប់វិស័យទាំងអស់ និងនៅតាមតំបន់ដាច់ស្រយាល" ក៏ប៉ុន្តែ មានស្ត្រីជាច្រើនរស់នៅតំបន់ដាច់ស្រយាល ពីមានឱកាសតិចតួច រហូតគ្មានឱកាសសោះ ក្នុងការធ្វើឲ្យប្រសើរឡើងនូវភាពមាំទាំផ្នែកសេដ្ឋកិច្ចរបស់ខ្លួន ដោយសារការកម្រិតពីក្រុមគ្រួសារ និងកង្វះការបណ្តុះបណ្តាល ការអប់រំ និងជំនាញ។

រាជរដ្ឋាភិបាលកម្ពុជា អះអាងថា ឃុំ/សង្កាត់នីមួយៗ គួរមានស្ត្រីយ៉ាងតិចម្នាក់ ទទួលបន្ទុកខាងផ្នែកកិច្ចការស្ត្រី និងកុមារ តាមរយៈគណៈកម្មាធិការសម្រាប់ស្ត្រី និងកុមារ។ ស្ត្រីទទួលបន្ទុកកិច្ចការនេះ គួរតែធ្វើការតស៊ូមតិលើគោលនយោបាយសម្រាប់សហគមន៍របស់ខ្លួន។ មិនមានព័ត៌មានណាមួយបង្ហាញ ថាតើការលើកឡើងនេះ បានកើតឡើងឬយ៉ាងណានោះទេ។

រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតមជ្ឈមណ្ឌលស្ត្រីចំនួន ១១ កន្លែង នៅទូទាំងប្រទេសកម្ពុជា ដើម្បីផ្តល់ព័ត៌មានដល់ស្ត្រីអំពីការបណ្តុះបណ្តាលវិជ្ជាជីវៈ និងមុខជំនួញ។ ដោយមិនមានទិន្នន័យផ្តល់ឱ្យបន្ថែមទៀត ទាក់ទងនឹងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលទាំងនេះ ប្រសិទ្ធភាពនៃមជ្ឈមណ្ឌលទាំងនោះ នៅតែជាការមួយត្រូវធ្វើការស្វែងយល់។

របាយការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា មិនបានលើកឡើងពីបញ្ហាសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភ ដល់ប្រជាពលរដ្ឋនៅជនបទ រីឯស្ត្រីនៅជនបទនៅតែបន្តខ្វះអាហារូបត្ថម្ភជាងស្ត្រីនៅទីប្រជុំជន ដោយសារកង្វះម្ហូបអាហារ ក៏ដូចជាសារជាតិចិញ្ចឹមសំខាន់ៗផងដែរ។

រាជរដ្ឋាភិបាលកម្ពុជា បានលើកឡើងនូវកម្មវិធីកម្ចីខ្នាតតូច ដែលត្រូវបានបង្កើតឡើងជាពិសេសសម្រាប់ជួយដល់ប្រជាពលរដ្ឋនៅតាមជនបទ ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច។ កម្មវិធីនេះបានផ្តល់នូវ "កម្ចីសរុប ៥,៥៦ ពាន់លាន រៀល ដល់ប្រជាពលរដ្ឋចំនួន ១១.៦៦១ នាក់ រួមមានស្ត្រីចំនួន ៨.៨៥២ នាក់ នៅក្នុងភូមិគោលដៅចំនួន ២៩៨"។ មានការព្រួយបារម្ភអំពីនីតិវិធីនៃការអនុវត្តប្រាក់កម្ចីខ្នាតតូចនៅក្នុងប្រទេសកម្ពុជា៖ ជារឿយៗ ការធ្វើផែនការ ឬការអប់រំតិចតួចអំពីហិរញ្ញវត្ថុ កម្ចី សេដ្ឋកិច្ច និងការចំណាយឲ្យមានប្រសិទ្ធភាព មុននឹងផ្តល់ប្រាក់កម្ចីដូច្នេះ គ្រួសារជាច្រើនបានធ្លាក់ខ្លួនជំពាក់បំណុលកាន់តែច្រើន។

ជម្រកនៅក្នុងតំបន់តាំងទីលំនៅថ្មីរបស់រាជរដ្ឋាភិបាល ដែលអ្នករងពីការបណ្តេញចេញដោយបង្ខំ បានចូលទៅរស់នៅ គឺមិនមានតម្រូវការជាមូលដ្ឋានគ្រប់គ្រាន់ និងខ្វះខាតជាទូទៅលើគ្រប់ផ្នែកទាំងអស់។

ការនិយមរំលោភយកដីធ្លីនាពេលបច្ចុប្បន្ន បានផ្តល់នូវផលអវិជ្ជប្រកបដោយភាពមិនស្មើគ្នាដល់ស្ត្រី។ នៅពេលដែលគ្រួសារមួយបាត់បង់ដីធ្លីរបស់ខ្លួន បុរសជាស្វាមីនឹងទៅស្នាក់នៅទីក្រុង ដើម្បីស្វែងរកការងារធ្វើ ខណៈដែលគ្រួសាររបស់គាត់ ត្រូវបានបញ្ជូនទៅនៅតំបន់ថ្មី។ ស្ត្រីជាអ្នកទទួលរងគ្រោះពីរដង ដោយទីមួយ គឺបាត់បង់ផ្ទះសម្បែង និងដីរបស់ខ្លួន ហើយនិងទីពីរគឺបាត់បង់ស្វាមី និងអ្នកផ្គត់ផ្គង់ក្នុងគ្រួសារ។ ស្ត្រីងាយនឹងរងគ្រោះពីអំពើហិង្សាផ្លូវភេទ និងកំណើនអត្រានៃរោគញៀនស្រា។

រាជរដ្ឋាភិបាលកម្ពុជា បានធ្វើការសន្និដ្ឋានថា យោងតាមកម្មវិធីរបស់ខ្លួន ស្ថានភាពស្ត្រីនៅតាមជនបទនឹងមានភាពប្រសើរឡើង ប៉ុន្តែមិនបង្ហាញពីគោលដៅ ឬកាលបរិច្ឆេទពេលណាដែលភាពប្រសើរនឹងសម្រេចបាន និងមិនមាននីតិវិធីសម្រាប់ធ្វើការត្រួតពិនិត្យ និងសំរាប់ធ្វើការវាយតម្លៃ។

សម្រាប់ស្ត្រីជនជាតិដើមភាគតិច បញ្ហាធំបំផុតដែលអ្នកទាំងនោះកំពុងប្រឈម គឺការបណ្តេញចេញដោយបង្ខំពីដីធ្លីរបស់ពួកគេ ដែលរួមទាំងការបំផ្លាញបរិស្ថាន និងធនធានធម្មជាតិ ដែលបណ្តាលមកពីការរីករាលដាលនៃការរំលោភយកដីធ្លី។ ប្រទេសកម្ពុជា បានផ្តល់ដីសម្បទាន ដែលមានទំហំធំៗទៅដល់ក្រុមហ៊ុនឯកជនយ៉ាងច្រើន ក្រោមទម្រង់ជាដីសម្បទានសេដ្ឋកិច្ច សម្រាប់គោលបំណងធ្វើកសិឧស្សាហកម្ម ជីកយករ៉ែ និងបង្កើតវារីអគ្គីសនី។ គម្រោងទាំងនេះ បានបង្កឲ្យមានការរំលោភបំពានជាលក្ខណៈប្រព័ន្ធទៅលើបុគ្គល និងសិទ្ធិសមូហភាពរបស់សហគមន៍ដែលរងផលប៉ះពាល់ ដូចជា ការផ្លាស់ប្តូរទីលំនៅដោយបង្ខំ ការគំរាមកំហែង និងការធ្វើទុក្ខបុកម្នេញទៅលើប្រជាពលរដ្ឋជនជាតិដើមភាគតិចដែលធ្វើការតវ៉ា និងបានបង្កឲ្យបាត់បង់របរចិញ្ចឹមជីវិតរបស់អ្នកទាំងនោះទៀតផង។

## មាត្រា ១៥៖ ភាពស្មើគ្នាចំពោះមុខច្បាប់ និងក្នុងបញ្ហារដ្ឋប្បវេណី

សាក្សីកម្មរបស់ស្ត្រីនៅក្នុងតុលាការ គឺតែងតែមិនមានភាពស្មើគ្នាជាមួយសាក្សីកម្មរបស់បុរស។ ស្ត្រីដែលជាជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារ តែងតែបង្ហាញពីភាពខ្វះជំនឿលើកម្លាំងមានសមត្ថកិច្ច និងតុលាការ ដែលជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តច្បាប់ទាំងនេះ។ ស្ត្រីជាជនរងគ្រោះ ត្រូវមានឯកសារជាច្រើនពាក់ព័ន្ធនឹងការទទួលរងរបួស ដើម្បីបង្ហាញជាភស្តុតាងពីករណីបណ្តឹងរបស់អ្នកទាំងនេះ។ នៅក្នុងករណីជាច្រើន ស្ត្រីជាជនរងគ្រោះនឹង

មិនស្វែងរកយុត្តិធម៌នោះទេ ដោយសារអ្នកទាំងនេះ ខ្វះជំនឿលើប្រព័ន្ធយុត្តិធម៌ ឬដោយសារការចំណាយខ្ពស់លើការដាក់បណ្តឹងទៅតុលាការ។ អារម្មណ៍ដែលមានភាពមិនប្រាកដប្រជាទាំងនេះ មិនមែនគ្មានមូលហេតុមកសំអាងនោះទេ មូលហេតុនោះគឺថា ស្ត្រីជាជនរងគ្រោះទទួលរងបញ្ហាប្រឈមជាច្រើនផ្សេងគ្នានៅក្នុងតុលាការ ដូចជា វិសមភាពយេនឌ័រនៅគ្រប់លំដាប់ថ្នាក់នៃប្រព័ន្ធតុលាការ ប្រការនេះដាក់បន្ទុកក្នុងការស្វែងរកភស្តុតាងលើការទទួលខុសត្រូវរបស់អ្នកទាំងនេះ។ ចំពោះរឿងក្តីលែងលះ ស្ត្រីត្រូវតែធ្វើការផ្សះផ្សារពីរទៅបីដង នៅមុខតុលាការ។ ជារឿយៗ តុលាការតែងតែដាក់សម្ពាធឲ្យស្ត្រីផ្សះផ្សាជាមួយស្វាមី ដោយណែនាំឲ្យស្ត្រីជាម្ចាស់បណ្តឹងមានភាពអត់ធ្មត់ និងមានការយោគយល់។ ក្នុងករណីនៃអំពើហិង្សាក្នុងគ្រួសារជាច្រើន តុលាការតែងតែសន្មត់ថា ស្ត្រីជាអ្នកខុសព្រោះថាជាអ្នកផ្តើមធ្វើឲ្យស្វាមីមានកំហឹង។

## មាត្រា ១៦៖ ភាពស្មើគ្នានៅក្នុងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ

ច្បាប់កម្ពុជាស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ មានកថាខណ្ឌជាច្រើន ដែលមានលក្ខណៈរើសអើងដោយបន្ទាបស្ត្រីមិនឲ្យស្មើបុរស។ នៅកម្ពុជា ស្ត្រីមិនមានសិទ្ធិលើទ្រព្យសម្បត្តិស្មើនិងបុរសទេ។ ទោះបីជាមាត្រា ៧០ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ អនុញ្ញាតឲ្យស្ត្រីទទួលបានទ្រព្យសម្បត្តិបន្ទាប់ពីលែងលះ ប៉ុន្តែបញ្ហាដែលកើតមានជាធម្មតានោះ គឺថាកម្មសិទ្ធិលើដីធ្លីរួមគ្នា នៅពេលខ្លះ ឈ្មោះស្វាមីត្រូវបានបញ្ចូលក្នុងប័ណ្ណកម្មសិទ្ធិដីធ្លី ដោយមិនមានការដឹងលឺពីប្រពន្ធ ហើយបុរសជាប្តីអះអាងថា ខ្លួនមានកម្មសិទ្ធិលើដីធ្លីពីតាំងដំបូង នៅបន្ទាប់ពីរំលាយចំណងអាពាហ៍ពិពាហ៍។ យោងតាមច្បាប់នេះ ស្ត្រី និងបុរស មានកាតព្វកិច្ចស្មើគ្នាក្នុងការថែរក្សាកូន។ នៅក្នុងករណីដែលបុរសចាកចេញពីស្ត្រីជាប្រពន្ធ ទៅរកស្ត្រីមួយផ្សេងទៀត ឬក៏ព្រោះបុរសជាស្វាមីត្រូវបញ្ជូនទៅពន្ធនាគារ ស្ត្រីជាភរិយាតែងតែទទួលរងនូវការចិញ្ចឹមបីបាច់កូន ដោយមិនមានជំនួយផ្នែកហិរញ្ញវត្ថុនោះទេ។ យោងតាមការស្រាវជ្រាវដែលធ្វើឡើងដោយកម្មវិធីស្បៀងអាហារពិភពលោក បង្ហាញថា នៅប្រទេសកម្ពុជា មានគ្រួសារចំនួន ៣០ ភាគរយ គឺស្ត្រីអ្នកដឹកនាំគ្រួសារ។

ស្ត្រីមានឱកាសតិចតួចក្នុងការជ្រើសរើសគូស្រករ ដោយសារអាពាហ៍ពិពាហ៍ត្រូវបានរៀបចំទុកដាក់ពីឪពុកម្តាយ និងស្ត្រីក្លាយជាកូនក្រមុំទាំងនៅវ័យជាកុមារ នៅតែបន្តកើតមានជាទូទៅក្នុងប្រទេសកម្ពុជា។ ក្នុងករណីជាច្រើន ប្រសិនបើ ក្មេងស្រីមានអាយុក្មេងខ្លាំង នោះ

គ្រួសារ និងបុរសជាស្វាមី ធ្វើការសូកប៉ាន់អាជ្ញាធរក្នុងភូមិ ឲ្យក្លែងបន្លំអាយុកំណើតក្មេងស្រីទាំងនេះ។

ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ បានចែងថា៖ " ប្តី ឬ ប្រពន្ធ អាចប្តឹងសុំលែងលះគ្នាបាន កាលបើមានមូលហេតុគ្រប់គ្រាន់បញ្ជាក់ថា ខ្លួនពុំអាចរួមរស់ជាមួយគ្នាតទៅទៀតបាន"។ នៅក្នុងការអនុវត្តជាក់ស្តែង ចំពោះស្ត្រីមានការលំបាកកាន់តែច្រើនឡើងក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍ ដូចជាការចំណាយ កង្វះឯកសារចាំបាច់ និងការធ្វើដំណើរឆ្ងាយ ប្រការទាំងនេះ ជារឿយៗត្រូវបានលើកឡើងថា ជាឧបសគ្គក្នុងការលែងលះសំរាប់ស្ត្រី។ ស្ត្រីជាជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារ មានជម្រើសតិចតួច ដើម្បីគេចចេញ។ អ្នកទាំងនេះតែងតែត្រូវបានបង្ខំឲ្យបន្តចំណងអាពាហ៍ពិពាហ៍ ដោយសារមូលហេតុផ្លូវច្បាប់ និងសេដ្ឋកិច្ច។ ករណីអំពើហិង្សាក្នុងគ្រួសារជាច្រើននៅតាមទីជនបទ កម្រនឹងត្រូវបានគេរាយការណ៍ណាស់។ ច្បាប់ស្រី បានលើកឡើងថាស្ត្រីគួរតែរក្សាទុករឿងរ៉ាវរបស់ខ្លួននៅក្នុងផ្ទះ។ នេះគឺជាសម្ពាធ ក្នុងការរក្សា "មុខមាត់" ដើម្បីជៀសវាងមិនឲ្យមានភាពអាម៉ាសនៅក្នុងសហគមន៍។ បញ្ហានេះជះឥទ្ធិពលដល់គ្រប់ឋានៈសង្គមទាំងអស់។ ទោះបីជានៅពេលស្ត្រីរាយការណ៍អំពីអំពើហិង្សាក្នុងគ្រួសារក៏ដោយ ក៏អាជ្ញាធរតែងតែឈរនៅខាងភាគីស្វាមី និងងាយស្រួលក្នុងការទទួលយកប្រាក់កម្រៃដើម្បីបញ្ចប់រឿងក្តី។ ស្ត្រីជាច្រើន បាននិយាយថា ពួកគាត់មានអារម្មណ៍ខ្មាស់អៀន នៅពេលរាយការណ៍អំពីអំពើហិង្សាក្នុងគ្រួសារទៅអាជ្ញាធរជាបុរស។ ស្ទើរតែគ្រប់អាជ្ញាធរទាំងអស់និយាយថា ពួកគាត់មិនមានសមត្ថភាពក្នុងការដោះស្រាយបញ្ហាអំពើហិង្សាក្នុងគ្រួសារទេ ព្រោះពួកគាត់មិនបានទទួលការបណ្តុះបណ្តាលនោះទេ។ អំពើហិង្សាផ្នែកសេដ្ឋកិច្ច និងផ្លូវចិត្ត ក៏ជាបញ្ហា ហើយក៏មិនត្រូវបានលើកឡើងនៅក្នុងច្បាប់កម្ពុជាផងដែរ។ នៅក្នុងច្បាប់កម្ពុជា មិនមានបញ្ញត្តិណាមួយចែងពីកិច្ចការពារខ្លួននោះទេ។ មានករណីជាច្រើន ដែលស្ត្រីត្រូវបានជាប់ពន្ធនាគារ ដោយសារបានសម្លាប់ស្វាមីរបស់ខ្លួន ដែលកើតចេញពីអំពើហិង្សាក្នុងគ្រួសារ។

ជារឿយៗ ជនប្រព្រឹត្តបទល្មើស រួចផុតពីការទទួលទោស ដោយប្រើប្រាស់នូវអំណាច និងការសូកប៉ាន់ ដើម្បីជៀសវាងពីការកាត់ទោស។ ក្នុងឆ្នាំ ២០១២ បុរសដែលរងការចោទប្រកាន់ពីបទជួញដូរផ្លូវភេទត្រឹមតែ ២៣ ភាគរយប៉ុណ្ណោះ ដែលបានឃុំខ្លួន។ ជារឿយៗ នៅពេលដែលស្វាមីជាប់ពន្ធនាគារពីបទប្រើអំពើហិង្សាក្នុងគ្រួសារ ស្ត្រីជាភរិយាមិនអាចលែងលះបានទេ ដោយសារមូលហេតុហិរញ្ញវត្ថុ។ នៅអំឡុងពេលដែលបុរសជាស្វាមីជាប់នៅក្នុង

ពន្ធនាគារ ស្ត្រីជាភរិយាមិនបានទទួលការគាំទ្រពីរាជរដ្ឋាភិបាលនោះទេ និងតែងតែអនុញ្ញាតឲ្យស្វាមីវិលត្រឡប់មកវិញបន្ទាប់ពីត្រូវបានដោះលែង។ ក្នុងចំណោមករណីទាំង ៣១៣ ដែលបានរាយការណ៍ទៅអង្គការអាដ ហុក នៅឆ្នាំ ២០១២ មាន ៦៨,២% ករណីបានផ្តល់ផលប៉ះពាល់ដល់កូនដែលមានអាយុពី ៥ ទៅ ១៨ ឆ្នាំ។

ដើម្បីកាត់ទោសបុរសប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ ទាល់តែមានភស្តុតាងបង្ហាញអំពីអំពើហិង្សា សាក្សី ក៏ដូចជារូបថតពីការរងរបួសនានា។ បញ្ហានេះបានរាំងស្ត្រីពីការស្វែងរកជំនួយដែលស្ត្រីត្រូវការ។ ចៅក្រមទទួលយកសំណូកពីជនជាប់ចោទ ជាថ្នូរនឹងការបន្ថយទម្ងន់ទោសមិនសូវជាធ្ងន់។ ទណ្ឌកម្មចំពោះការប្រើអំពើហិង្សាក្នុងគ្រួសារ គឺចាប់ពី ១ ឆ្នាំ ដល់ ៥ ឆ្នាំច្រើនបំផុត អាស្រ័យទៅលើភាពធ្ងន់ធ្ងរនៃអំពើហិង្សានោះ។ អង្គការមិនមែនរដ្ឋាភិបាល ដែលជួយដល់ជនរងគ្រោះជាស្ត្រីពីអំពីហិង្សាក្នុងគ្រួសារ ធ្វើការគ្របដណ្តប់ការងាររបស់ខ្លួន ភាគច្រើននៅទីក្រុងធំៗជាច្រើន ដោយទុកឲ្យស្ត្រីនៅជនបទមានជម្រើសតិចតួចប៉ុណ្ណោះ។

## អនុសាសន៍ទូទៅ ១៩៖ អំពើហិង្សាលើស្ត្រី

គួរកត់សម្គាល់ថា រាជរដ្ឋាភិបាលកម្ពុជាមិនបានលើកឡើងនូវអនុសាសន៍ទូទៅ ១៩ នៅក្នុងរបាយការណ៍ជាតិនោះទេ។

ស្ត្រីនៅកម្ពុជាទទួលរងគ្រោះពីអំពើហិង្សាលើយេនឌ័រ នៅស្ទើរគ្រប់ទិដ្ឋភាពនៃជីវិត។ ទស្សនៈវប្បធម៌ និងប្រពៃណីទៅលើស្ត្រី ដែលត្រូវបានចងក្រងនៅក្នុងច្បាប់ស្រី ជំរុញឲ្យស្ត្រីស្ថិតនៅក្រោមការបង្គាប់បញ្ជាជ្រុលហួសហេតុ។ អំពើហិង្សាក្នុងគ្រួសារ ការបៀតបៀនផ្លូវភេទ ការជួញដូរផ្លូវភេទ និងជួញដូរមនុស្ស បន្តកើតមានជាទូទៅនៅក្នុងប្រទេសកម្ពុជា។ ស្ត្រីប្រឈមមុខនឹងអំពើហិង្សាដែលកើតចេញពីប្រពៃណីវប្បធម៌ និងអំពើពុករលួយនៅក្នុងប្រព័ន្ធយុត្តិធម៌។ អំពើហិង្សាក្នុងគ្រួសារ នៅតែបន្តកើតមានយ៉ាងច្រើន។ មានការដាក់ទណ្ឌកម្មតិចតួចទៅលើជនប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ ដោយសារអំពើពុករលួយក្នុងប្រព័ន្ធយុត្តិធម៌ ក៏ដូចជាកង្វះការយល់ដឹងពីច្បាប់ ជាពិសេសនៅតាមជនបទនានា។ អសន្តិសុខហិរញ្ញវត្ថុ គឺជាមូលហេតុចំបងដែលរាំងស្ត្រីក្នុងការដាក់ពាក្យបណ្តឹងលែងលះ។ ការជួញដូរផ្លូវភេទ គឺជាបញ្ហាដ៏ធំមួយ។ ជារឿយៗ ក្មេងស្រីមួយចំនួនត្រូវបានឪពុកម្តាយ ឬសាច់ញាតិលក់តាំងពីក្មេងទៅក្នុងការជួញដូរផ្លូវភេទ ដែលក្មេងស្រីខ្លះមានអាយុត្រឹម ៥ឆ្នាំ។ ឧបសគ្គចំបងមួយ ក្នុងការ

ប្រយុទ្ធប្រឆាំងនឹងការជួញដូរផ្លូវភេទ និងការធ្វើពេស្យាចារដោយបង្ខំនៅកម្ពុជា គឺមកពីការរកចំណូលបានយ៉ាងច្រើនពីអំពើទាំងនេះ និងមកពីមន្ត្រីនគរបាលរាជរដ្ឋាភិបាលកម្ពុជាពុករលួយ។ យោងតាមអ្នកជំនាញខ្លះបានបង្ហាញថា ចំនួនប្រាក់ចំណូលនៅក្នុងការជួញដូរផ្លូវភេទនៅកម្ពុជា គឺមានប្រហែល មួយភាគបីនៃផលិតផលជាតិសរុប (GNP) របស់ប្រទេសកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជា ទទួលស្គាល់ថាការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ នៅតែកើតមានឡើង ហើយបានលើកឡើងនូវកម្មវិធីមួយចំនួនសមស្របដើម្បីលុបបំបាត់បញ្ហានេះ ដូចជា "ពង្រឹងសមត្ថភាពតុលាការក្នុងការអនុវត្តពាក្យបណ្តឹងពាក់ព័ន្ធនឹងករណីជួញដូរមនុស្សឲ្យកាន់តែមានភាពច្បាស់លាស់ និងមានប្រសិទ្ធិភាព ហើយជំរុញឲ្យមានការស្វែងរក និងមានការស៊ើបអង្កេតឲ្យកាន់តែសកម្មលើករណីជួញដូរមនុស្សនានា"។ ប៉ុន្តែ នៅក្នុងរបាការណ៍ជាតិមិនបានលំអិតឲ្យបានច្បាស់ពីវិធីសាស្ត្រដែលនឹងធ្វើឲ្យសម្រេចនូវគោលដៅទាំងនេះនោះទេ។